# សង្គ្រាម គ្នាឯង ?

## ព្រះស្រីសុគន្ធបទ - ស្តេចកន - ព្រះចន្ទរាជា

**មាតិការឿង**


អារម្មណ៏កថា........................................................................2

ដើមចម នៃ សង្គ្រាម..................................................................5

តើ ការសងសឹកនោះ ជា ការការពារខ្លួន ?.......................................5

ករណី របស់ ស្តេចកន..................................................................6

អត្ថធិប្បាយ ..........................................................................19

ករណី របស់ ព្រះចន្ទរាជា ...........................................................22

ចុះប្រសិនបើជា យុទ្ធសាស្ត្រ របស់ព្រះចៅសៀម ?..................................23

អត្ថធិប្បាយ ..........................................................................26

សាច់រឿង (scénario).................................................................51

តើមូលហេតុអ្វី បាន ជា ស្តេចកន ចាញ់ ព្រះចន្ទរាជា ?..........................53


ឧប សៅ សន្ធា    ការសោកល្បែង    ២២ សីហា ២០២០

# សង្គ្រាម ក្នាឯង

## អារម្ភណ៍កថា

អត្ថបទនេះ គឺ ខ្ញុំ សរសេរ បន្ត ពី ការសាកល្បង របស់ខ្ញុំ ដែល មាន ប្រធានបទ « អ្នកតាឃ្លាំងមឿង » ជា សេចក្ដីបន្ថែម នៃ សង្គ្រាម របស់ ស្ដេចកន (១៥១២-១៥២៥) ជាមួយ ព្រះស្រីសុគន្ធបទ (១៥០៤-១៥១២) និង ព្រះចន្ទរាជា (១៥១៦-១៥៦៧) នៅ សតវត្ស ទី១៦។ សំនួរ ផុសនៅក្នុង គំនិតខ្ញុំ គឺ តើ សង្គ្រាម ទាំងពីរ លើកនោះ មាន ដើមចម បែបណា ? ការជជីកនេះ នាំឱ្យខ្ញុំ ប្រារព្ធ[1] សរសេរ ដើម្បី ជា ប្រីជា[2] អំពី ដើមហេតុនោះ សំរាប់ ខ្លួនឯងផ្ទាល់ និង ចែក ដល់ អស់អ្នកផង។

យើងដឹងថា សង្គ្រាម មាន ដើមចម ពីរយ៉ាង៖ សង្គ្រាម ការពារ និង សង្គ្រាម ឈ្លានពាន, ហើយ សង្គ្រាមនោះ ជួនជា សង្គ្រាម ក្នាឯង (guerre civile) ជួនជា សង្គ្រាម ជាមួយ បរទេស។ សង្គ្រាម ដែល មាន កើតឡើង រវាង ស្ដេចកន ជាមួយ ស្ដេចទាំងពីរអង្គ គឺ ជា សង្គ្រាម ក្នាឯង មាន រយះពេល ប្រមាណ ១៤ ឆ្នាំ រហូតមាន បែងចែក ស្រុកខ្មែរ ជា ពីរដំបន់ នយោបាយ និង យោធា គឺ តំបន់ ខាងលិច ត្រួតត្រា ដោយ កងទ័ព ស្ដេច ពេញរាជវង្ស និង ខាងកើត ត្រួតត្រា ដោយ រាស្ត្រ ប្រកាសខ្លួន ជា ស្ដេច។ ស្ដេច ទាំងសងខាង សុទ្ធតែមាន ប្រជារាស្ត្រ គាំទ្រ រៀងៗខ្លួន ផ្ញើ

[1] ប្រារព្ធ : កិ. ផ្ដួចផ្ដើម, តាំងផ្ដើម, ផ្គងជាមុន, និយាយតំណាលអំពីរឿងដើម។

[2] ប្រីជា : ន. ប្រាជ្ញា, ការកំណត់ដឹង, សេចក្ដីដឹងច្បាស់លាស់, ការយល់ជាក់។

**សង្គ្រាម គ្នាឯង**

សឹកសង្គ្រាម ទាំងអស់ (guerre totale) ព្រោះ កេណ្ឌ រាស្ត្រប្រជា ធ្វើជាទាហាន ហើយ បញ្ជាឱ្យ រាស្ត្រ នឹង រាស្ត្រ ចូល កាប់ប្រចាក់គ្នា នៅលើសមរភូមិ ដោយគ្មានទុកជីវិត ឱ្យសត្រូវ ដែលជាខ្មែរដូចគ្នា។

នៅក្នុង រាជ្យ ព្រះបាទ ធម្មរាជា (១៤៧១-១៤៨៥) ដែល ជា ព្រះរាជាបិតា របស់ ព្រះស្រីសុគន្ធបទ និង ព្រះចន្ទរាជា, ស្រុកខ្មែរ មាន សន្តិភាព បន្ទាប់ ពីមាន សង្គ្រាម ដែល ព្រះស្រីរាជា (១៤៣៣-១៤៨៥) ជា ព្រះជេដ្ឋា របស់ ព្រះធម្មរាជា លើក ទ័ពទៅច្បាំងនឹង សៀម នៅ ស្រុកសៀម នៅ ឆ្នាំ ១៤៥៣ ហើយ បន្ទាប់មក មាន សង្គ្រាម គ្នាឯង រវាង ស្តេច បីអង្គ គឺ ព្រះស្រីរាជា, ព្រះធម្មរាជា និង ព្រះស្រីសុរិយោទ័យ ជា ភាគិនេយ្យ[3] របស់ ស្តេច ទាំងពីរអង្គ ដើម្បី ដណ្តើម រាជបល្ល័ង្ក គ្នា។ សង្គ្រាម នោះ ចប់សព្វគ្រប់ ដែល មាន ទ័ពសៀម គេ លើកមកជួយ ព្រះធម្មរាជា តាម សំណើរ របស់ ស្តេចនោះ ហើយ ព្រះចៅសៀម ចាប់ ស្តេច ពីរអង្គ ជា គូសឹកនឹង ស្តេច ដែលខ្លួន ទំនុកបម្រុង យកទៅស្រុកសៀម នៅឆ្នាំ ១៤៧១។ បើគិតពី ឆ្នាំ ផ្តើមសង្គ្រាម នៅឆ្នាំ ១៤៥៣ ដល់ ឆ្នាំ ១៤៧១ សង្គ្រាម ទាំងពីរដងនោះ មាន រយៈពេល ប្រមាណ ១៨ ឆ្នាំ។ ដូច្នេះ នៅក្នុង សន្តតិវង្ស ព្រះបាទ ពញាយ៉ាត ចាប់ ពី ព្រះស្រីរាជា មក ដល់ ព្រះចន្ទរាជា មាន សង្គ្រាម អស់រយៈពេល ប្រមាណ ៣២ ឆ្នាំ ជា សង្គ្រាម គ្នាឯង នាំបង្កើត ទុក្ខវេទនា ដល់ ប្រជារាស្ត្រ និង បំផ្លាញ ធនធានជាតិ

---

3 ភាគិនេយ្យ : ក្មួយប្រុស។

## សង្គ្រាម គ្នាឯង

ច្រើនក្រៃ នាំឱ្យ ប្រជាជាតិខ្មែរ កាន់តែ ទន់ខ្សោយ ហើយ បើក ទ្វារ លាភជ័យ ដល់ ប្រទេស ជិតខាង មាន យួន និង សៀម ដែល គេ តែងតែ មាន លោភចិត្ត ទឹកដី មកលើ ផែនដីខ្មែរ។ ដូច្នេះឯង រាល់ ជម្លោះ រវាង ខ្មែរ នឹង ខ្មែរ វា ជា សាច់ចំណេញ ដល់ បរទេស ដែល គេ សន្សំទុក បង្កើតបាន ជា ទឹកដី ដែល គេ ក្លាយជា ចៅទេស[4] ដូចយ៉ាង ទឹកដី កម្ពុជាក្រោម និង នៅ ភាគ អាគ្នេយ៍ នៃ ប្រទេសសៀម សព្វថ្ងៃ។ ការពិតនេះ វា ជា សមរ[5] ជា ស្រណោក នៅក្នុង អារម្មណ៍ របស់ អស់ជនខ្មែរ រហូត មកដល់សព្វថ្ងៃនេះ។ ពាក្យ ថា ស្រណោះ ដីខ្មែរ វា ជា ការបង្ហាញ ការបាត់បង់ ទឹកដី ជា ស្លាពរ នៅក្នុង អារម្មណ៍ អសកម្ម នោះ ឯង។ សង្គ្រាម គ្នាឯង បើមាន បរទេស ជា អ្នកដើមចម ឬ ជា អ្នកប្រដុងប្រជា វា ជា សំណាញ់បំណុល របស់ បរទេស ដែល អ្នក ឈ្នះ ត្រូវចាំបាច់ សងបំណុល អ្នកជួយខ្លួន នៅ ពេល មាន សន្តិភាព ដើម្បី រក្សា ជ័យជំនះ។ សន្តិភាព បែប នេះ បរទេស ជា អ្នកជួយ គេរើសយកអ្វីៗល្អៗអស់ ជា សំណង ជា កតវេទិតារី[6] នៃ ខ្មែរអ្នកឈ្នះ លើ ខ្មែរគ្នាឯង រីឯ អ្នកឈ្នះនោះ វិញ នៅតែ សំណល់ ដែល បរទេស គេ ទុកឱ្យ។ ឧទាហរណ៍ ព្រះចន្ទរាជា ទោះបី ព្រះអង្គ បដិសេធ មិន ទទួលស្គាល់ ឧបការគុណ របស់ ព្រះចៅសៀម តែ សៀម គេ ទទួលផលល្អ ជា ជម្រើស របស់គេ

---

4 ចៅទេស : ម្ចាស់ប្រទេស។

5 សមរ : ន. ការរញក, ការចងចាំ, ដំណើរនឹកឃើញមិនភ្លេច។

6 កតវេទិតា : ដែលគិតតែនឹងតបស្នងគុណដល់អ្នកមានគុណ។

# សង្គ្រាម គ្នាឯង

លើ ទុក្ខវេទនា នៃ ប្រជាពលរដ្ឋខ្មែរ នៅពេល សង្គ្រាម និង បន្ទាប់ ពី សង្គ្រាម ដែល វា ជា ផលប្រយោជន៍ របស់គេ សំរាប់ អនាគតកាល។ ផលប្រយោជន៍នោះ គឺ ទុរពល ពុំអាចបង្វិល វិញបាន នៃ ប្រជាជាតិខ្មែរ។ ឧទាហរណ៍ បែបនេះ វា មាន កើត មាន បន្តៗ រហូត មកដល់ សព្វថ្ងៃនេះ។

## ដើមចម នៃ សង្គ្រាម

សង្គ្រាម រវាង ព្រះស្រីសុគន្ធបទ និង ព្រះចន្ទរាជា ជាមួយនឹង ស្តេចកន មាន ដើមចម គឺ ការសងសឹក។ ស្តេចកន សងសឹក ព្រះស្រីសុគន្ធបទ ព្រោះ ព្រះអង្គ មាន បំណង សម្លាប់ខ្លួន, រីឯ ព្រះចន្ទរាជា វិញ ទ្រង់ សងសឹក ស្តេចកន ព្រោះ នរនេះ ដណ្តើម រាជបល័ង្ក របស់ រាជវង្ស របស់ខ្លួន។

## តើ ការសងសឹកនោះ ជា ការការពារខ្លួន ?

បើ មិនរៃ គឺ ច្បាស់ ជា មើលឃើញថា ការសងសឹងនោះ ជា ការ ការពារខ្លួន (légitime défense)។ ដែល អាចទុក ជា ការការពារខ្លួន វា ត្រូវមាន លក្ខខណ្ឌ ៦ យ៉ាង :

- ការវាយប្រហារតបវិញ ត្រូវមាន លក្ខណៈ មិនសមហេតុ ផល គឺថា ដោយគ្មានហេតុផលត្រឹមត្រូវ,
- ការការពារខ្លួន គឺ ប្រព្រឹត្តិឡើង សំរាប់ ខ្លួនឯង ឬ សំរាប់ អ្នកដទៃ,
- ការការពារខ្លួន ត្រូវតែ ជាបន្ទាន់,

# សេចក្ដីបញ្ចប់ ត្រូវឯង

- ការការពារខ្លួន ត្រូវតែចាំបាច់ សំរាប់ សវត្ថិភាពខ្លួន គឺថា មាន ដំណោះស្រាយ តែមួយគត់ គឺ ត្រូវតែ តបវិញ,
- ការការពារខ្លួន ត្រូវតែមាន សមាមាត្រ។

ដូច្នេះ ការការពារខ្លួន របស់ ព្រះចន្ទរាជា និង ស្ដេចកន វា មិន ឆ្លើយស្របទាំងអស់នឹង លក្ខខណ្ឌ ទាំង ៦ យ៉ាង ដែលបាន រៀបរាប់ ខាងលើនោះឡើយ។

## ករណី របស់ ស្ដេចកន

ស្ដេចកន ក្រោយពីបាន រត់គេចខ្លួនរួច ពី គំរោង ធ្វើឃាតខ្លួន របស់ ព្រះស្រីសុគន្ធបទ ក៏ទៅបញ្ចុះបញ្ចូល ពួកពលព្រះ និង បថុជ្ជន ទាំងឡាយ បង្កើត ជា កងពល ដោយ លើកយក មូលហេតុ ថា សំរាប់ ច្បាំងនឹង ព្រះចន្ទរាជា ដែល មាន បំណង ក្បត់នឹង ព្រះរាជា។ រួចហើយ ស្ដេចកន បើកការវាយប្រហារ ខេត្តមួយ ចំនួន នៅក្រោម ការត្រួតត្រា របស់ ព្រះចន្ទរាជា ប្រកបដោយ ជោគជ័យ។ ជ័យជំនះ បន្តបន្ទាប់ របស់ នរនោះ នាំឱ្យ ព្រះចន្ទរាជាភិតភ័យ ក៏ព្រះអង្គសំរេចចិត្តរត់ភៀសខ្លួនទៅស្រុកសៀម។ ហេតុផល ដែល ព្រះអង្គ លើកឡើង គឺ ស្ដេចកន ពិត ជា ទទួល បញ្ជា ពី ព្រះរាម ឱ្យកេណ្ឌទ័ព វាយប្រហារខ្លួន ដោយ ចោទ ប្រកាន់ថា ខ្លួន ជា មនុស្សក្បត់ នឹងព្រះអង្គ។ បន្ទាប់មក ស្ដេចកន តែងតែ ធ្វើ ការសន្យា ជាមួយ ព្រះស្រីសុគន្ធបទ តាម សំណើរ របស់ ព្រះអង្គ ថា ខ្លួននឹង រំសាយទ័ព ហើយ វិលត្រឡប់ មក បំរើ ព្រះរាជា វិញ។ តែ ការសន្យានោះ វា គ្រាន់តែ ការពន្យារ

# សង្គ្រាម ត្រាឯង

ពេល ដើម្បី ពង្រីក និង ពង្រឹង កងទ័ព ដើម្បី វាយប្រហារ ព្រះរាជា តែប៉ុណ្ណោះ។ យើងដឹងថា ស្តេចកន ប្រើគ្រប់ ល្បិចកល ដើម្បី ច្បាំង យកឈ្នះ ព្រះរាជា ដែលត្រូវ ជា បងថ្លៃ របស់ខ្លួន ក្នុង គោលបំណង ផ្តាប់មុខ ដណ្តើម រាជបល្ល័ង្ក ព្រោះ គ្រូ បាន ទាយ ថា ខ្លួន នឹងឡើង គ្រងរាជសម្បត្តិ។ រីឯ ព្រះស្រីសុគន្ធបទ វិញ នៅពេលចាប់ផ្តើម នៃ ជម្លោះអាវុធ ព្រះអង្គ ក្តុលគំនិត ក្នុង ការស្វែងរក នៃ ការផ្សះផ្សារ ជាមួយ ស្តេចកន ដោយ សង្ឃឹម ថា មាតា បិតា និង បង ស្រី របស់ ស្តេចកន ដែល រស់នៅ នៅក្រោម មេត្តាធម៏ របស់ព្រះអង្គ នឹងអាច កៀងគរ នរនោះ ឱ្យដាក់ អាវុធ ឈប់ ប្រឆាំង នឹងព្រះអង្គ។ ការសង្ឃឹម ដោយមាន សុទ្ធចិត្ត ក្តី ឬ ជា ឧបាយកល ក្តី របស់ ព្រះសុគន្ធបទ វា មិនអាច កៀងគរ ស្តេចកន បាននោះឡើយ បើគិតដល់ ចរិក មិនស្លិតស្លេរ របស់ ស្តេចនេះ ដូចយ៉ាង យក សុបិននិមិត្ត ធ្វើ ជា ការពិត និង យក ក្បួនទាក់ទិន[7] ជា ដំណោះស្រាយ។ មិនគ្រាន់តែមិនជឿ, ស្តេចកន តែងតែគិត នៅក្នុងចិត្ត ថា ស្តេចនេះ ល្ងង់ណាស់, បើល្ងង់យ៉ាងនេះ គង់នឹងអញ ដណ្តើម បានរាជសម្បត្តិមកអញហើយ។ មួយវិញទៀត ស្តេចកន ប្រើភាពខ្លៅ របស់ ព្រះស្រីសុគន្ធបទ ជា យុទ្ធសាស្ត្រ របស់ខ្លួន ដូច

---

[7] ទាក់ទិន : ឈ្មោះតម្រាហោរមួយប្រភេទ សម្រាប់គន់គូរ ពិនិត្យមើលកាលល្អអាក្រក់ : ក្បួនទាក់ទិន ឬ តម្រាតាក់ទិន។

យ៉ាង ប្រើ ខ្ញុំរាជាការ ជា ស្ត្រី រូបល្អ[8] មក លួងលោមចិត្តខ្លួន តែស្តេចកន ទាញយកប្រយោជន៍ ពី គំនិត រាក់កន្ទេលនេះ ដោយប្រកាស នៅចំពោះមុខ ប្រជានុរាស្ត្រ ដែល ស្ម័គ្រ ចូលបំរើខ្លួនថា ៈ ព្រះស្រីសុគន្ធបទ ត្រាស់បង្គាប់ បម្រើស្ត្រីនោះ នាំ ព្រះរាជចុតហ្មាយ មក ប្រាប់ខ្លួន ឱ្យគិតការណ៍ សម្លាប់ ព្រះចន្ទរាជាដែល ជា ស្តេចក្បត់។ ឃើញ បម្រើស្ត្រី របស់ ព្រះរាជា មករឿយៗដូច្នេះមែន, ប្រជានុរាស្ត្រ ក៏នាំគ្នាជឿ ថា រឿងនេះ ជាការពិត។ យុទ្ធសាស្ត្រនេះ ហុច ប្រយោជន៍ ដល់ ស្តេចកន ច្រើនយ៉ាង ៈ ទី១. បញ្ចុះបញ្ចូល អាណាប្រជានុរាស្ត្រ ហើយ មាន ពេល បង្ហាត់ សេនាទាហាន បានជាច្រើន កើតចំនួនឡើងតែរាល់ថ្ងៃ, ទី២. បំបែកព្រះចន្ទរាជា ពី ព្រះរាជា គឺថា ជំរុញ ព្រះអនុជ ឱ្យរត់ភៀសខ្លួនទៅស្រុកសៀម ចោល ព្រះជេដ្ឋារាជ, ទី៣. នាំឱ្យ ព្រះរាជា ពន្យារពេល បង្កើតទ័ព ដើម្បី លើកមកច្បាំងនឹងខ្លួន នៅពេល ដែលខ្លួន កំពុងកទ័ព ច្បាំងនឹង ព្រះអង្គ។ ថ្វីគំនិតនេះ គឺ ជា ត្រីមុខនៃ នយោបាយសឹក របស់ ស្តេចកន ដែលនាំគាត់ ទៅរក ជ័យជំនះ ដែល គ្មាន នរណា អាចនឹកស្មានបាន គឺថា រាស្ត្រ អាចច្បាំងឈ្នះ ស្តេច។

---

[8] ព្រះស្រីសុគន្ធបទ នឹកស្មានថា ប្រើឱ្យស្ត្រី រូបល្អ ទៅ លួងលោម ចិត្ត ស្តេចកន ព្រោះ នរនេះ ជា មនុស្សល្មោភកាម ប្រហែល ជា វា នឹងអាចដូរចិត្ត។

## សង្គ្រាម គ្នាឯង

ព្រះចន្ទរាជា ឮដំណឹង ថា ព្រះរាជា បញ្ជាឱ្យ ស្តេចកន កេណ្ឌទ័ព ដើម្បី ច្បាំងនឹងព្រះអង្គ ប៉ែរ ជា គិត គ្មានការពិចារណា ក្នុង ឋានៈ ជា ឧបរាជ ថា ៈ

- ពាក្យ ដែលឮនេះ ប្រហែលជាមែន បានជា សម្តេចព្រះជេដ្ឋារាជ ធ្វើព្រងើយកន្តើយ ឱ្យបម្រើស្រី ទៅមកយ៉ាងនេះ ណ្ហើយចុះ បើព្រោះតែយើងមួយ យើង នឹងនៅឱ្យគេទើសទាល់រវល់ថ្វី។

ថ្វីបើ ជា គំនិត ជៀសវាង ជម្លោះ តែ ជា ចរិត គ្មាន តក្កភាព (logique) នោះឡើយ រហូត អាចទុក វាបាន ជា ការកំសាក ថែមទៀតផង។ ក្នុង ឋានៈ ជា ឧបរាជ រាជកាតព្វកិច្ច របស់ ព្រះចន្ទរាជា ត្រូវតែ កទ័ព ជា បន្ទាន់ សម្រាប់ បំរុង វាយប្រហារតបនឹង ស្តេចកន ដែល បង្កើត សង្គរ ភ្លើន នៅក្នុង ព្រះរាជាណាចក្រ, រួចថ្វាយ ដំណឹង ដល់ ព្រះជេដ្ឋារាជ ហើយ រង់ចាំ រាជបញ្ជាសឹក។ ប៉ុន្តែ ព្រះចន្ទរាជា បែរជា ធ្វើផ្គុយស្រឡះ ពីអ្វី ដែល ជា កាតព្វកិច្ច របស់ទ្រង់ ដែលនាំឱ្យ បែក កម្លាំង ព្រះរាជវង្សានុវង្ស នៅចំពោះ សត្រូវ របស់ រាជ្យ។

រាល់លើក ព្រះស្រីសុគ្គបទ តែងតែ ត្រាស់សួរ ព្រះស្នំឯក ជា បងស្រី ស្តេចកន ថា ៈ

- ប្អូនឯង ម្តេចក៏ពុំឃើញចូលមក តើឯង ឮ ដំណឹង ម្តេចដែរ ?

# មេរៀន ខ្លាងឯម

ព្រះនាង កេសរបុប្ផា ក្រាបទូលថា៖

- ខ្ញុំម្ចាស់ឱ្យបម្រើទៅតឿនវា វាថា កុំភ័យនឹងវា វាមិនក្បត់ទេ។ ថាកាលណា វាជូនរាស្ត្រទៅស្រុករួចហើយ វានឹងចូលមកក្រាបបង្គំគាល់។ ឥឡូវស្រាប់តែបាត់ទៅ ចាំព្រឹកនេះ ខ្ញុំម្ចាស់នឹងចាត់ បម្រើ ឱ្យទៅតឿនវាទៀត។

ភាពពាយងាយ នៅក្នុងគំនិត របស់ ព្រះស្រីសុគន្ធបទ បែបនេះឯង ជា ជោគ របស់ ស្តេចកន។

ចំណែក ប្រជានុរាស្ត្រ ជឿ ស្តេចកន ព្រោះ ទុក នរនេះ ជា មនុស្ស មាន បុណ្យ និង ជា អ្នកចេះដឹង ល្បីល្បាញមួយ នៅក្នុងព្រះរាជាណាចក្រ។ ថោមភាព[9] នេះ ដែល ស្តេចកន ទុក ជា សម្ភារ[10] ដើម្បី បំរើ ផលប្រយោជន៍ របស់ខ្លួន។

នៅពេល ស្តេចកន លើកទ័ព មកបោះ នៅចុង ខែត្រ ស្រីសឈរ ទើប ព្រះស្រីសុគន្ធបទ ភ្ញាក់ខ្លួន ថា គ្រប់ ការសន្យារ របស់ កន ជា ល្បិច ពន្យាពេល តែប៉ុណ្ណោះ។ ព្រះអង្គ ត្រាស់បញ្ជាឱ្យ ចៅពញា យោធាសង្គ្រាម កេណ្ឌទ័ព លើកទ័ពស្រួច ទៅច្បាំងនឹងកន តែ ត្រូវ នរនេះ បាញ់ធ្នូ ត្រូវដើម-ក ហើយ ធ្លាក់ពីលើដំរី ស្លាប់មួយរំពេច។ ទ័ពភូមិន្ទ មួយកងពលធំទៀត ដឹកនាំដោយ ចៅពញាចក្រី ក៏កាល់ពល ទាហាន ទ័ពស្រួច បែករត់

---

9 ថោមភាព : ភាពដែលគួរសរសើរ, ការស្ញើច ឬ កោតសរសើរតម្កើងដោយសារមានជោគជ័យ។
10 សម្ភារ : ន. ការសាងសន្សំបន្ទុំបារមី។

# សង្គ្រាម ត្លាឯខ

ថយក្រោយ ឱ្យចូលប្រយុទ្ធ ជាថ្មី ជាមួយ ទាហាន របស់ខ្លួន តែច្បាំងមិឈ្នះនឹង កងទ័ព ស្តេចកន ក៏ដកថយ មកធ្វើ ជាខ្សែការពារ កុំឱ្យ ទ័ពសត្រូវ វាយប្រហារ ចូល ព្រះរាជធីនី។ រី ព្រះរាជាត្រូវ បាន មេទ័ពធំ អញ្ជើញព្រះអង្គ ឱ្យថយ ទៅឯក្រុងចតុមុខសិន ដើម្បី សវត្ថិភាពព្រះអង្គ។ នៅពេល ប្រជុំ រកដំណោះស្រាយទប់ទល់នឹង ទ័ព ស្តេចកន, ព្រះពិជ័យនាគ ជា បិតា ស្តេចកន សូមខ្លួន ចេញ ទៅតដៃនឹងកូន។ ព្រះស្រីសុគន្ធបទ យល់ព្រមដោយ ប្រគល់ ទាហាន ១ ពាន់នាក់។ មុននឹង លើកទ័ពចេញច្បាំង ព្រះរាជា ឱ្យធ្វើពិធី ផឹកទឹកសប្បថ ដោយប្រកាស ថា៖ បើទូលព្រះបង្គន់ ក្បត់នឹងព្រះរាជា សូមឱ្យទូលព្រះបង្គន់ ស្លាប់ តែនឹងត្រូវគ្រឿងសស្ត្រាវុធ ហើយ សូមឱ្យសម្លាប់ បុត្រ ភរិយា ញាតិសន្តាន ទូលព្រះបង្គំ ជា ខ្ញុំទាំងអស់ តាម សព្វព្រះរាជហឫទ័យ។ ស្តេចកន លុះដឹងថា ព្រះរាជា នាំទ័ពហ្លួង ដកថយ ចោលទីក្រុង ក៏ លើករេហ៍ពល ចូលវាយ ទ័ព ចៅពញាចក្រី បែកទ័ព ហើយ សម្លាប់ មេទ័ពនេះ បាន។ បន្ទាប់មក វាយលុកចូលក្នុង រាជធានី, ខណៈនោះ នាយទ័ព ស្តេចកន បានជួបប្រទះនឹង កងពល បិតា របស់ ស្តេចកន លើកមក តទទឹងនឹងទ័ពខ្លួន ក៏បញ្ជាឱ្យ រេហ៍ពល ចូលប្រយុទ្ធ តែហាមដាច់ខាត មិនឱ្យប៉ះពាល់ដល់ ព្រះពិជ័យនាគ។ ច្បាំង បានមួយស្របក់ ទ័ព របស់ ព្រះពិជ័យនាគ ចាញ់ដៃ ក៏ដកថយ រត់ទៅពួន នៅក្នុងវត្ត។ ដឹងដំណឹងនេះ ព្រះគ្រូ របស់ ស្តេចកន ក៏និមន្ត មក ផ្សះផ្សា បិតាឱ្យដាក់អាវុធ ចូលរួមនឹងបុត្រ។ នៅពេល ចាប់ផ្តើម នៃ ការ

# សង្គ្រាម ភ្លាងខ

សន្ធនា មាន វគ្គមាន ស្តេចកន, ព្រះពិជ័យនាគ បដិសេធ ដោយលើក ហេតុផល ថា បើ ខ្ញុំ ធ្វើ ដូច្នេះ ច្បាស់ ជា ព្រះរាជា សម្លាប់ គ្រួសារ របស់ករុណា ជា ពុំខាន។ តែ សិល្ប: នៃ ការ ពន្យល់ របស់ សម្តេចព្រះសុគន្ធាធិបតី ធ្វើឱ្យ ព្រះពិជ័យនាគ ទន់ចិត្ត ហើយ ក៏យល់ព្រម សះជានឹងកូន។

មិនឱ្យខាតពេលវេលា ស្តេចកន ចាត់ចែងនាយទ័ព ឱ្យចេញ កេណ្ឌរាស្ត្រ និង សង្កត់ខេត្តធំតូច នៅត្រើយខាងកើតទាំង អស់ ហើយ ឱ្យប្រមូលកងពលមកជួបជុំ លើក ទ័ព ជើងគោក ជើងទឹក សន្ធឹកមហិមា ឆ្លងទន្លេ ទៅវាយទ័ពភូមិន្ទ នៅ បន្ទាយភ្នំពេញ។ ទ័ព ស្តេចកន មានចំនួន ៥ម៉ឺននាក់ វាយរេហ៍ ពល ជារបង ហុមព័ទ្ធ បន្ទាយ ភ្នំពេញ ដែល មាន ទាហាន ហ្លួង ៣ម៉ឺននាក់ ជា អ្នកការពារ។ ព្រះស្រីសុគន្ធបទ មិនតក់ស្លុត នឹង ចំនួនទ័ពសត្រូវ ព្រះអង្គ ត្រាស់បញ្ជា ឱ្យនាយទ័ព ទទួល ច្បាំងនឹងស្តេចកន អស់រយ:ពេល ៣ ថ្ងៃ តែពុំឈ្នះចាញ់សោះ។ ដូច្នេះ ស្តេចកន ប្រមូល ទ័ពបំរុង ចូលវាយ ជាជំនួយ ដល់ទ័ព ដែល កំពុងច្បាំង, ប្រជុំគ្នា កើន ចំនួន ជាង ១សែននាក់ មាន ទាំង កាំភ្លើងធំផង ចូលវាយ និង បាញ់ បន្ទាយ ភូមិន្ទ គ្មាន ស្គាល់ យប់ថ្ងៃ។ យល់ឃើញថា ទ័ពសត្រូវ កំពុង មាន ប្រៀប លើ ទ័ពព្រះអង្គ ហើយ កងទ័ពខាងទ្រង់ ក៏ចេះតែរត់មិនទទួល ច្បាំងសោះ, ព្រះស្រីសុគន្ធបទ ក៏ថយទ័ព ទៅតាំង នៅ ខេត្ត ល ង្វែក។ បន្ទាប់ពី វាយបន្ទាយភ្នំពេញបែកហើយ ស្តេចកន បញ្ជា

# សង្គ្រាម ភ្លាងខ

ឱ្យនាយទ័ព ទៅសង្កត់ ខេត្ត ខាងត្បូង និង ខាងលិច គឺ ខេត្ត បាទី, ព្រៃក្របាស, ទ្រាំង, បន្ទាយមាស, កំពត, កំពង់សោម, បាសាក់, ព្រះត្រពាំង, ឱម៉ោ, ក្រមួនស, ទឹកខ្មៅ រៀងដល់ ខេត្ត ព្រៃនគរ, បារៀន, ដូណាយ, លង់ហោ, ផ្សារដែក។ ប្រជានុរាស្ត្រ សឹងចុះចូល ស្តេចកន ទាំងអស់ ព្រោះ មាន ជំនឿ ផ្កាប់មុខ ថា កន ជា អ្នកមានបុណ្យ។ បន្ទាប់មក កន ចាត់ឱ្យនាយទ័ព លើក រេហ៍ពល មាន ចំនួន ៤ម៉ឺននាក់ ទៅវាយ បន្ទាយ លង្វែក។ ហើយ កងទ័ពមួយទៀត មាន ចំនួន រេហ៍ពល ៣ម៉ឺននាក់ ឆ្លងទន្លេធំ ទៅសង្កត់ ខេត្ត ខាងលិច។ ព្រះស្រីសុគន្ធបទ ចាត់ឱ្យ ពញាក្រឡាហោម នាំ ទ័ព មាន ចំនួន យោធា ១ម៉ឺននាក់ ទៅ ខាងលិច ជា បន្ទាន់។ ព្រះអង្គ ទុក ទាហាន តែ ២ម៉ឺន ៥ពាន់នាក់ សំរាប់ ការពារ បន្ទាយលង្វែក។ បន្ទាយនោះ ត្រូវបាន កងទ័ព ស្តេចកន ចោមវាយ អស់រយៈពេល ៤ ថ្ងៃ ពុំឈប់ឈរសោះ។ ព្រះរាជា ទ្រង់យល់ឃើញថា នឹងទ្រាំទប់ទល់ទៀតពុំបាន ទើបទ្រង់ ថយទ័ព ទៅតាំងនៅខែត្រ អម្រាគគិរិន្ទបូណ៌ (គឺស្រុកបរិបូណ៌សព្វថ្ងៃនេះ)។ ឃើញដូច្នេះ ទ័ព ស្តេចកន ក៏លើកដេញប្រកិតទ័ពហ្លួង។ ពញាក្រឡាហោម ដឹងថា សត្រូវកំពុង ដេញតាម ទ័ពហ្លួង ក៏ បត់ក្បាលទ័ព មកជួយព្រះរាជាវិញ ដោយ វាយសត្រូវ ពីខាងក្រោយ។ ដឹងដំណឹងនេះ ព្រះរាជា ក៏ត្រាស់បញ្ជាឱ្យនាយទ័ព ត្រឡប់ក្រោយ ចូល វាយសត្រូវ ពីខាងមុខ។ ការវាយផ្ទប់ ទាំងខាងមុខក្រោយនេះ នាំឱ្យទាហានសត្រូវស្លុតស្លាប់ជាច្រើន អន្តរាយបែកទ័ព រត់ត្រឡប់ចូលមកភ្នំពេញ

## សង្គ្រាម គ្នាឯង

វិញ។ បរាជ័យនេះ ក៏ហុចឱកាសឱ្យ ទ័ពភូមិន្ទ មាន ចៅពញា យមរាជ ជា មេទ័ព លើកទ័ព វាយ ខែត្រ បារាយណ៍, ជើងព្រៃ, កំពង់សៀម, ស្ទឹងត្រែង ឈ្នះសត្រូវ។ ជាប្រញាប់ ស្តេចកន កេណ្ឌទ័ពបន្ថែមទៀត បង្កើត ជាកងទ័ពថ្មី មាន ទង់ទ័ព ពណ៌ក្រហម មាន ប៉ាក់ រូបនាគ មាន ក្បាល៨ ហើយ តាំងខ្លួន ជា មហាឧបរាជ បាំងក្លស់ដូចព្រះមហាក្សត្រ។ ចាប់ពីពេលនោះឯង ដែល ប្រជានុរាស្ត្រ ហៅ កន ថា ស្តេចកន។ រៀបចំទ័ពសព្វគ្រប់អស់ហើយ, ស្តេចថ្មីនេះ ក៏លើកទ័ព ទៅវាយទ័ពហ្លួង តាំងនៅ ខែត្រ អាសន្ទុក តែ ទុក បិតា ឱ្យនៅរក្សា បន្ទាយ ស្រុកបាសាន។ លើកទ័ព មកដល់ ខែត្រ កំពង់សៀម ស្តេចកន ក៏ចាត់បម្រើឱ្យនាំសារ ថ្វាយ ព្រះស្រីសុគន្ធបទ មាន ស្នើរ ជា លក្ខខណ្ឌ ដោយ ទុក ព្រះអង្គ ជាមនុស្សល្ងង់ ថា បើ ព្រះរាជា ប្រគល់គ្រួសារខ្លួន ដែល ជាចំណាប់ខ្មាំង របស់ព្រះអង្គ ជាមុនមក ឱ្យខ្លួន ខ្លួន នឹងរំលាយទ័ព ហើយ ចូលខ្លួន មកបំរើ ព្រះរាជា ជា ធម្មតាវិញ។ តែ ត្រូវ ព្រះរាជា បដិសេធ ដោយ បញ្ជាឱ្យ ស្តេចកន រំលាយទ័ពជាមុនសិន និង ចូលខ្លួនមកថ្វាយបង្គំព្រះអង្គ។ ស្តេចកន ទទួលបាន ចម្លើយ អវិជ្ជមាននេះ ក៏ប្រញាប់ ឱ្យសេនាសារ ទៅជូនដំណឹង ដល់បិតា។ ព្រះជ័យនាគ ឮបម្រើ ថា មាន សារពីកូន ក៏ស្ទុះរត់ ទៅទទួល តែមកទន្ទឹមនឹងទ្វារ ក៏ភ្លាត់ជើង ដួល ហើយ ទៅត្រូវនឹងចុងដាវ ដែលដាក់នឹងដៃកែរចំចន្លោះឆ្អឹងដងកាំបិត ហើយដួលចុះ សន្លប់បាត់ស្មារតី។ ស្តេចកន ដឹងដំណឹងអកុសលនេះ ក៏ថយទ័ព មកស្រុកបាសានវិញ

# សង្គ្រាម ត្លាងខ

តែ មិនទាន់ដង្ហើម បិតា[11]។ ស្ដេចកន ប្រកាសផ្អាកសង្គ្រាម
ហើយ ចាត់ចែង រៀបចំ ធ្វើបុណ្យសពបិតា ជាឧឡារិក។ ចំណែក
ព្រះស្រីសុគន្ធបទ ដឹងដំណឹង ថា ព្រះជ័យនាគ ក្ស័យជីវិត ដោយ
អាវុធ ក៏នឹកក្នុកថា ប្រហែល រាសី កំពុងឡើង ក៏ត្រាស់បញ្ជាឱ្យ
នាយទ័ព លើកទ័ព ទៅវាយ យក ខែត្រ ត្បូងឃ្មុំ, បន្ទាយលង្វែក
និង កំពង់សៀម ដោយ បំពាន ប្រពៃណី គឺថា នៅពេល មេស
ត្រូវ ធ្វើបុណ្យសព បិតា ឬ មាតា ក៏គួសត្រូវ គេតែងឈប់ធ្វើស
ង្គ្រាម កំណត់យ៉ាងតិចមួយថ្ងៃសិនដែរ។ កាលបានដឹងថា ព្រះ
ស្រីសុគន្ធបទ បំពាន ប្រពៃណីនេះ ស្ដេចកន ក៏ស្រើបស្រាល ជា
សេចក្ដីក្សេមក្សាន្ត ពន់ប្រមាណ ព្រោះ គាត់ យល់ឃើញ ថា បើ
ព្រះរាជា ធ្វើល្មើស បទអយ្យការយ៉ាងនេះហើយ គឺច្បាស់ជា ស្ដេ
ចនេះ អស់បុណ្យជាពិត។ យល់ឃើញ បែបនេះហើយ ស្ដេចកន
ក៏បញ្ជាឱ្យ ខ្ញុំរាជា ធ្វើពិធីជប់លៀង ហើយនៅពេលនោះ ពួកម
ន្ត្រីសេនាទាហាន មួយក្រុម ក៏ទះដៃ តាំងហ៊ោថា៖ ពួកយើង
អម្បាញ់មិញនេះ ឃើញនាគមួយ ហោះព័ន្ធរោងបុណ្យ ៣ជុំ, ការ
ណ៏នេះពិត ជា បាតុភូត អស្ចារ្យ ថា ចៅហ្វាយយើង មហា
ឧបរាជ ជា អ្នកមានបុណ្យ ពីអតីតមក។ ឮគេហ៊ោដូច្នេះ រេហ៍
ពលទាំងអស់ ក៏ហ៊ោ តៗព្រមគ្នា ហើយ ស្រែក ថា ពិតជា ត្រូវ

---

11 មរណភាព ដោយ អាវុធនោះ អ្នកខ្លះ មានជំនឿ ថា ព្រះជ័យនាគ ចាញ់សប្បថខ្លួន ចំពោះ ព្រះស្រីសុគន្ធបទ។

## សង្គ្រាម ត្រាងខ

ដូចទំនាយ ថា ម្ចាស់យើង នឹងឡើង គ្រងរាជសម្បត្តិ នៅក្រុង កម្ពុជា ជាពុំខាន។

ធ្វើបុណ្យសព បិតា ចប់សព្វគ្រប់ហើយ, ស្ដេចកន លើកទ័ព ៣ ផ្លូវ មាន ចំនួន ប្រមាណ ១ សែននាក់ សំដៅទៅ ខែត្រ អាសន្ទុក។ លើកមកដល់ ចុងខេត្តនោះ, កន គិតថា បើនឹងចូលច្បាំង អាចនឹងឈ្នះ ព្រោះ លើកនេះ រេហ៍ពល របស់អញ កំពុង មាន គោលចំណង់ ចង់ច្បាំងនឹង ស្ដេច អគតិ តែ ច្បាស់ជា ព្រះស្រីសុគន្ធបទ ឱ្យសម្លាប់ ម្ដាយ និង ញាតិសន្ដាន ជា ការសងសឹកពិត, ដូច្នេះ ត្រូវ រក កល បញ្ឆោត ហ្លួង លូង់ក្លៅនេះសិន ក្រែង បានសម្រេច។ ឧបាយ របស់ ស្ដេចកន គឺ បញ្ជូន កងពិសេស មួយកង ចូលទៅសម្លាប់ ហ្លួង នៅក្នុង បន្ទាយជ័យ តែម្ដង។ ពិត ជា ឧបាយ លលា[12] តែ ឧបាយបែបនេះ ជួនកាល វា ធ្វើឱ្យគូសត្រូវ មិនអាចនឹកស្មានបាន។ គិតគូរ និង ដេញប្រយោគ គ្រប់ជ្រុង នៃ ផែនការ ជាមួយ នាយកងទ័ព រួចស្រេចអស់ហើយ, ស្ដេចកន សួររក នាយពល ស្ម័គ្រចិត្ត ម្នាក់ សំរាប់ សង្ហរ[13] កងពលពិសេស ចំនួន ២ រយ នាក់ ចូល ទៅក្នុង បន្ទាយហ្លួង។ ខណៈនោះ ឧកម៉ឺន សុរិន្ទកែវ ជា កូន របស់ ចៅពញាយោធាសង្គ្រាម ដែល ស្ដេចកន បាញ់ធ្នូត្រូវ-ក ធ្លាក់ពីលើខ្នងដំរីស្លាប់ហើយ ស្ដេចកន ចាប់ កូននោះបាន តែ មិនយកទោសពៃរ៍ ជា

12 លលា : គុ. ពក្លីពភ្លើ, insensé។
13 សង្ហរ : កិ. ដឹកនាំ។

## សង្គ្រាម ត្រាឯង

ឈ្លើយសឹក បែរ ជា មានចិត្ត សន្ដោស ដល់ នរនោះ ដោយ បំពាក់ យសស័ក្ក ជា នាយទាហាន នៅក្នុង កងទ័ព របស់ខ្លួនទៅវិញ។ ឧបាយកល របស់ ស្ដេចកន គឺ ធ្វើឱ្យ ឧកម៉ឺន សុរិន្ទកែវ នាំ រេហ៍ពល របស់ខ្លួន រត់ចូលខ្នាំង ដោយសារខ្លួន ទទួលទោស ដោយ អយុត្តិធម៌បំផុត ហើយ ខ្លួន ក៏ជា កូន របស់ សព មន្ត្រី នាយសេនាម្នាក់ ធ្លាប់បំរើ តត្រកូល រាជវង្សានុវង្ស ដូច្នេះខ្លួន តែងតែ ចាំឱកាសល្អ នឹង រត់វិលត្រឡប់ មក បំរើ ជា ខ្ញុំរាជាការ ព្រះមហាក្សត្រ វិញ។ ទន្ន្បីករណ៍ ទាំងឡាយនេះ វា នាំចិត្ត ចៅពញា ឧទ័យធិរាជ ជា នាយទ័ព ជួរមុខ របស់ហ្លួង ជឿ ក៏ បញ្ជូនខ្លួន ឧកម៉ឺន សុរិន្ទកែវ និង រេហ៍ពល ២ រយនាក់ ទៅ បន្ទាយជ័យ នៅ ស្ទឹងសែន ទៅក្រាបបង្គំ ទូលថ្វាយ ហ្លួង ដើម្បី សុំព្រះរាជវិនិច្ឆ័យ តាមច្បាប់សឹក។ ព្រះស្រីសុគន្ធបទ ទ្រង់ ត្រាស់ បង្គាប់ មន្ត្រី ក្រុមមឿង ជា ក្រុមរក្សាព្រះអង្គ និង ក្រុម មហាផ្ទៃ ឱ្យពិចារណា សួរកត់យកចម្លើយ ឈ្មោះទាំងនោះ ម្នាក់ ម្ដងៗ។ លុះឃើញថា ចម្លើយ របស់ទាហាន ទាំង ២ រយនាក់នោះ ឆ្លើយដូចៗគ្នា តាម សំបុត្រ ចៅពញាឧទ័យធិរាជ ពិត, ក៏ថ្វាយ សេចក្ដីរាយការណ៍ ដល់ព្រះរាជា។ ព្រះអង្គ ក៏ឱ្យលើកទោស ហើយ ទុកឱ្យរេហ៍ពល ទាំងនោះ បំរើ នៅក្នុង កងរក្សាព្រះអង្គ ទៅ។ កាលដឹងថា ព្រះស្រីសុគន្ធបទ ចូលក្នុង អន្ទាក់កល របស់ខ្លួន ហើយ ស្ដេចកន ក៏លើកទ័ព ចោមវាយ បន្ទាយ ចៅពញាឧទ័យ ធិរាជ យ៉ាងសាហាវ។ ទ្រាំច្បាំងពុំបាន នាយទ័ពនេះ ក៏នាំទ័ព ដោះថយ ទៅ ស្ទឹងសែន ហើយ រៀបចំ ទូកចំណុះ និង ទូកចម្លង

ត្រៀមទុក ដើម្បីនឹងអញ្ជើញ ព្រះស្រីសុគន្ធបទ ទៅគង់នៅឯខែត្រពោធិសាត់។ លុះដឹងថា ចៅពញាឧទ័យធិរាជ រៀបចំផែនការដូច្នេះ, ឧកម៉ឺន សុរិន្ទកែវ និង ពលសេនា នៅវេលារាត្រី ក៏នាំគ្នា ចូលវាយ ព្រះរាជដំណាក់ ដោយប្រើ ល្បិចកល ថាមាន ដំណឹងពិសេស មកថ្វាយព្រះរាជា។ ចូលដល់ក្នុងបរិវេណកាលណា ក៏វាយប្រហារ កងរក្សាព្រះរាជា គ្មានសំចៃដៃឡើយ។ ចៅពញាយមរាជ ឮសន្ធឹកអាវុធ ក៏ប្រញាប់ នាំពលសេនា ទៅជួយ តែ ពុំទាន់ ព្រោះ ព្រះស្រីសុគន្ធបទ ត្រូវបាន ឧកម៉ឺន សុរិន្ទកែវ ធ្វើឃាតព្រះអង្គ រួចទៅហើយ។ ចៅយោមរាជ លុះដឹងថា ព្រះស្រីសុគន្ធបទ ព្រះសុគតហើយ ក៏អញ្ជើញ ចៅពញាយសរាជ[14] ដែល ជា បុត្រាមកុដ របស់ សព ហ្លួង រត់ចុះទូក បោះបង់បន្ទាយទាំងយប់ ដើម្បី ទៅស្រុកសៀម, តែដល់ពាក់កណ្ដាលផ្លូវ ក៏ឈឺអនិច្ចកម្មទៅ។ អស់មុខមន្ត្រី ដែល រត់ចេញពីបន្ទាយជាមួយលោក ក៏បន្តដំណើរ ហែ ព្រះរាជបុត្រ ទៅក្រុងទេពទៅ។

ស្ដេចកន លុះដឹងថា ព្រះមហាក្សត្រ ទ្រង់សុគតហើយ និង ព្រះយោមរាជ រត់ចោលបន្ទាយ ក៏លើកទ័ព វាយប្រហារ ទ័ពភូមិន្ទ តែ ទ័ព នៅក្នុង បន្ទាយ គ្មាន មេកង ត្រួតត្រា ក៏នាំគ្នារត់ខ្ចាត់ខ្ចាយទៅ។ ព្រះមហាឧបរាជ កន បានឡើងប្រាប្ដាភិសេកសោយរាជសម្បត្តិ ក្នុង ឆ្នាំរកចត្វាស័ក ព.ស. ២០៥៦ ត្រូវនឹង គ

---

14 ពញាយសរាជ ត្រូវជា បុត្រ របស់ព្រះស្ដំឯក, ដូច្នេះ ព្រះអង្គ ត្រូវជា ក្មួយ របស់ ស្ដេចកន។ នៅពេលនោះ ព្រះអង្គ ទើបតែមាន ព្រះជន្មាយុ ៥ ឆ្នាំ។ ព្រះយោមរាជ ត្រូវជា បិតាលៀង ( ឪពុកធម៌) របស់ព្រះអង្គ។

# មហ្រ្គាម ភ្នាំងខ

.ស. ១៥១២ ក្នុង ជន្មាយុ ២៩ ឆ្នាំ ក្នុង វាំងបាសាន ខែត្រ ស្រីសឈរ ទ្រង់ព្រះនាមថា ព្រះសម្តេច ព្រះស្រីជេដ្ឋរាជ រាមាធិបតី។ នៅឆ្នាំ ១៥១៤ ស្តេចកន ប្តូរ រាជធានី ពី ស្រុកបាសាន ទៅតាំងនៅ ចុងខែត្រត្បូងឃ្មុំ ទល់ដែន ខែត្របាភ្នំ ដាក់ឈ្មោះ ថា ក្រុងសន្ធប់ដូនតី ព្រៃនគរ ចររាជធានី។

## អត្ថាធិប្បាយ

អង្គហេតុ នៃ ឧទ្ទាមកម្ម របស់ ស្តេចកន តាំងពី ដំបូងទី រហូតដល់ ឡើងគ្រងរាជសម្បត្តិ វា មាន លក្ខណៈ ជា សកម្មភាព របស់ រាជ្យភង្គ[15] សុទ្ធសាធ។ ពិតណាស់ហើយថា ពីដំបូងទី ស្តេចកន មាន ប្រតិកម្ម ជា អ្នករងគ្រោះ នៅចំពោះមុខ អំពើ អយុត្តិធម៌ គឺ គោលបំណងខ្មៅ របស់ ព្រះស្រីសុគន្ធបទ ចង់សម្លាប់ខ្លួន ដោយគ្មាន ហេតុផល។ ដូច្នេះ ប្រតិកម្មនេះ វា អាចទុកជា ការសងសឹក ដើម្បី រកយុត្តិធម៌។ ពីដើមដំបូងទីដែរ, កន មាន ការគាំពារ ពី សម្តេច ព្រះសុគន្ធាធិបតី ជា សម្តេចសង្ឃ ដែល ជា ព្រះគ្រូ របស់ខ្លួន តាំងពីកុមារភាព។ គុណូបការនេះ វា ជា ជំនួយចិត្ត លួសលុប[16] ចំពោះកន នៅក្នុង ស្ថានភាពធ្ងន់ធ្ងរ គឺ ខ្លួន មាន វិបត្តិ ជាមួយ ស្តេចផែនដី។ តែនៅពេលនោះ អ្វី ដែល ជា អត្តគុណសម្បត្តិ របស់ កន គឺ ស្មារតីរឹង (sang-froid) និង ភាពវាងវៃ ជា អ្នកចេះដឹង ដែលនាំឱ្យ កន អាចប្រើ

---

15 រាជ្យភង្គ : អ្នកដណ្តើមរាជ្យ។
16 លួសលុប : មិនអាចដាក់តម្លៃបាន។

# មេត្រាម គ្នាឯង

បញ្ហា សំរាប់ ដោះស្រាយ បញ្ហា អាយុជីវិត, ដូចយ៉ាង កន រុករក ល្បិចកល សំរេចដោយផលល្អ ដែល មាន ស្នាម នៅក្នុង ប្រវត្តិសាស្ត្រ គឺ ព្រះពញាយ៉ាត ទ្រង់ ប្រើឧបាយ ឱ្យមនុស្ស ១២ នាក់ ចូលទៅ ធ្វើឃាត ព្រះឥន្ទកុមារាជា (ស្តេចសៀម) ដែល សោយរាជ្យ នៅ មហានគរ (១៣៨៤-១៣៨៥) យកមកប្រើ ឱ្យ ឧកម៉ឺន សុរិន្ទកែវ ចូលទៅធ្វើឃាត ព្រះស្រីសុគន្ធបទ នៅក្នុង បន្ទាយ ល្វែង បានដូចប្រាថ្នា។ ដូច្នេះ ប្រវត្តិសាស្ត្រ មិនមែន ជា កញ្ចក់ សំរាប់ ឆ្លុះមើល ព្រឹត្តិការណ៍ ពី អតីតកាល, តែ ជួនកាល វា ក៏ ជា ចុងជួននឹង ស្ថានភាព បច្ចុប្បន្ន ដែល អាចទុកជា គំនិតដ៏ ប្រសើរមួយ ដែល អាចយកមកប្រើបាន។ តែ ទោះបីយ៉ាងណា ប្រវត្តិសាស្ត្រ មិនអាចទុកជា មេរៀន, តែ វា ជា ព្រឹទ្ធាចារ្យ សំរាប់ មើលពិនិត្យពិនិស្ច័យ បញ្ហា បច្ចុប្បន្ន។

ប៉ុន្តែ កន ក៏មាន ជំនួយ ពី បងស្រី ដែល ហ៊ាន ក្បត់ ព្រះរាជា ជា ស្វាមី ដើម្បី ជួយសង្គ្រោះប្អូន ដោយប្រថុយជីវិត។ តែ គេ ក៏ អាច ទុក កន ជា មនុស្ស មានសំណាង តាំងពីកំណើត និង មាន វាសនា តាម ទំនាយគ្រូ ថា នឹងឡើងគ្រងរាជសម្បត្តិ។ ដូច្នេះ កន ជា បុគ្គល ចេះយកផលអំពី ចំណេះចេះដឹង, ជំនួយ, សំណាង និង វាសនា របស់ខ្លួន ដើម្បី ប្រែឱ្យចំរើនទៅ ជា កម្លាំង តស៊ូ ដាច់ខាត។ ទោះបី កន ប្រើ ឧបាយកល ជា ការ កុហក ដល់ ប្រជានុរាស្ត្រ ដោយ យក ព្រះនាម ព្រះរាជា ថា ស្តេច ឱ្យកេណ្ឌទ័ព ដើម្បី ច្បាំងនឹង ព្រះចន្ទរាជា ជា ព្រះអនុជ

# សង្គ្រាម ត្រាឯង

ដែល ទ្រង់ មាន បំណង ក្បត់រាជ្យ, តែ បើ កន ជា មនុស្សល្ងង់ វិធិវិរុទ្ធ[17]នេះ ប្រហែល ជាមិនអាច មាន ជោគជ័យ បាននោះដែរ។ ដូច ព្រះស្រីសុគន្ធបទ ព្រះអង្គ យក អារម្មណ៏ ជា ការពិត យក ឃាតកម្ម ជា មធ្យោបាយ, ដូចពាក្យកាព្យថា : យល់តូចកុំអាលខំ នោះយល់ធំ កុំអាលស្រាយ គិតក្តី កុំគិតងាយ មើលពិនិត្យពិនិស្ស័យ។ (សាស្ត្រាច្បាប់កេរ្តិ៍កាល)។ គេ ឃើញថា គ្រប់ដំណោះស្រាយ របស់ ព្រះស្រីសុគន្ធបទ ក្នុង វិបត្តិ ជាមួយ កន ក្តី ក្នុង ទំនាក់ទំនង ជាមួយ ព្រះអនុជ ក្តី ក្នុង បញ្ហា សឹក ក្តី គឺ ធ្វើឡើង គ្មាន ការពិចារណា។ ព្រះអង្គ យករឿង តូច ធ្វើ ធំ, យក បញ្ហា ធំ ទុកជា តូច ដែលនាំឱ្យ ព្រះអង្គ រស់នៅក្នុង ការបំភាន់ជានិច្ច។ ដូច្នេះ បន្តិចម្តងៗ គ្រប់បញ្ហា ដែល ព្រះអង្គ បានជួបប្រទះ វា ស្រមូល ដោះមិនរួច ដែល ហុច ឱកាស ឱ្យ កន ជា មនុស្សពិទ័គ្ន[18] ចេះឆ្នៃយកជាផលប្រយោជន៏ គឺថា ទុព្វលភាព របស់ព្រះអង្គ វា ជា កម្លាំង របស់ស្តេចកន។ ដើមឡើយ កន ប្រើ ការសងសឹង ជា គោលចំណង់ ព្រោះ ខ្លួន មាន កំហឹង ពេញសិទ្ធិ ជា ជនរងគ្រោះ ដោយ ស្វែងរក មធ្យោបាយ សំរាប់ ការពារខ្លួន ដោយ ប្រើ ប្រជាប្រិយភាព និង បញ្ញា របស់ខ្លួន ដើម្បី ធ្វើឱ្យសកម្ម នៃ ភព្វបុគ្គល[19] របស់ខ្លួន។ ផ្ទុយពី ព្រះស្រីសុគន្ធបទ ជា

17 វិធីវិរុទ្ធ : ខុសបែប, ដែលមិនចុះបែប។
18 ពិទ័គ្ន : គុ. ឈ្លាស, វាងវៃ, ប៉ុន, ប្រសប់។
19 ភព្វបុគ្គល : បុគ្គលដែលមានសំណាងល្អ។

## សង្គ្រាម ភ្នាំងខ

ភណ្ឌនការី[20] ប្រើ ការសង្ស័យ និង ការស្រមើស្រមៃ ជា មូលដ្ឋាន សំរាប់ ការពារខ្លួន ដែល ជា កត្តា នៃ បរាជ័យ របស់ព្រះអង្គ។

### ករណី របស់ ព្រះចន្ទរាជា

នៅពេលដែល ព្រះស្រីសុគន្ធបទ ជា ព្រះជេដ្ឋារាជ ធ្វើ សង្គ្រាម ជាមួយ ស្ដេចកន, ព្រះចន្ទរាជា ភៀសខ្លួន ទៅ រស់នៅ ស្រុកសៀម ប្រកបដោយ សុខក្សេមក្សាន្ត[21]។ តើ ព្រះអង្គ កោតខាម[22] ស្ដេចកន ទើបបាន រត់ចោលព្រះរាម ?

កាលដឹងដំណឹងថា ព្រះរាម សុគតហើយ, ព្រះចន្ទរាជា ក៏ក្រាបទូល សូមបង្គំលា សម្ដេចចៅចក្រពត្តិ ទៅបង្ក្រាប កន ដែលក្បត់ ញាំញីព្រះពុទ្ធសាសនា នូវ ព្រះបរមរាជវង្សានុវង្ស បណ្ដាលឱ្យបែកបាក់ខ្ចាត់ខ្ចាយអស់ ថា បើព្រះអង្គនឹងបង្អង់យូរទៅ ឃើញថា ពុំបានឡើយ។ ព្រះចៅសៀម ទ្រង់ត្រាស់ថាៈ កុំឱ្យក្ដួយរួសរាន់ពេក ចាំដល់ឆ្នាំក្រោយ។ ព្រះចន្ទរាជា បានឮព្រះក្រសែងដូច្នោះកាលណា ក៏យល់ថា ព្រះចៅសៀម មិនព្រមឱ្យព្រះអង្គវិលត្រឡប់ ទៅស្រុកខ្មែរឆាប់ឡើយ។

---

20 ភណ្ឌនការី : អ្នកបង្កជម្លោះ។

21 ព្រះចន្ទរាជា យាងទៅគង់ ស្រុកសៀម ពីឆ្នាំ ១៥០៨ ដល់ ឆ្នាំ ១៥១៥ ឃើថា មាន រយៈពេល ៧ ឆ្នាំ។

22 កោតខាម : កោតខ្លាច ទាំងគោរពផង។

# សង្គ្រាម ត្បាងឯង

## ចុះប្រសិនបើជា យុទ្ធសាស្ត្រ របស់ព្រះចៅសៀម ?

បើ ព្រះចន្ទរាជា អាចបោកប្រាស ព្រះចៅចក្រពត្តិ យកទ័ពសៀម ទៅធ្វើសង្គ្រាម នៅស្រុកខ្មែ បានងាយស្រួលបែបនេះ, តើព្រះចៅសៀម ជា មនុស្សអព្យត្ត[23] មែនឬ ?

ប៉ុន្តែ គេ អាចសួរថា ចុះបើ រឿង ឧបាយកល[24] របស់ ព្រះចន្ទរាជា សូមខ្លួន ទៅ ទាក់ដំរី-ស ថ្វាយ ព្រះចៅចក្រពត្តិ ជា យុទ្ធសាស្ត្ររួម រវាង ស្តេចទាំងពីរអង្គនេះ ទៅវិញ, លើចំណុចនេះ តើអ្វីទៅ ជា ផលប្រយោជន៍សៀម ?

ការឡើងគ្រងរាជសម្បត្តិ របស់ ស្តេចកន នៅស្រុកខ្មែរ វា ទុកជាការគំរាមមួយ ដល់ ស្រុកសៀម ព្រោះ រាជវង្សខ្មែរថ្មីនេះ វា របូតពី ឥទ្ធិពលសៀម ហើយ ស្តេចកន នឹងអាច មាន មហិច្ឆិតាជាតិ ធ្វើសង្គ្រាម ទាមទារ ទឹកដីខ្មែរ ដែល សៀម ត្រួតត្រា។ ព្រះចៅសៀម ទ្រង់ ព្យាករ ថា បើទុកឱ្យ ស្តេចកន ដែល ជា ជនមាន កេរ្តិ៍ឈ្មោះ ជា អ្នកមានបុណ្យ ឱ្យរៀបចំស្រុក បានមាំមួន និង ពង្រឹងអំណាច របស់ខ្លួន ជា ស្តេចចក្រពត្តិ, ការណ៍នេះ វា នឹងអាចឱ្យ ស្តេចកន មាន វេរភាព[25] នឹង ព្រះអង្គ នៅថ្ងៃណា

---

23 អព្យត្ត : (អ័ប-ព្យ័ត) គុ. ដែលមិនឈ្លាស, មិនប៉ិន, មិនវាងវៃ។

24 ឧបាយកល គឺ ទូទ័រ ដំណឹង ថាមាន ដំរីសដ៏ធំមួយ ដោយ ប្រើល្បិចបង្កើត ទំហែងច្បាស់ក្រឡែត នៃ ស្នាម ជើង លាមក រោម ដំរី តែ សុទ្ធជា ទំហែង ក្លែង។ បន្ទាប់មក ព្រះចន្ទរាជា ធ្វើជាអ្នកស្ម័គ្រចិត្ត ទៅទាក់ដំរីសនោះ ថ្វាយ ព្រះចៅសៀម តែព្រះអង្គ បែរ ជាយាង ចូលស្រុកខ្មែរតែម្តង ដើម្បីបង្ករទ័ពធ្វើសង្គ្រាមនឹងស្តេចកន ទៅវិញ។

25 វេរភាព : ន. ភាពបុគ្គលជាសត្រូវនឹងគ្នា។

# សង្គ្រាម គ្នាឯង

មួយមិនខាន។ ដូច្នេះ ការស្វែងរក នៃ សមគ្គចេតនា[26] ជាមួយ ព្រះចន្ទរាជា ជា យុទ្ធសាស្ត្រ ការពារ ទុកជាមុន វា ជា ករណីយកិច្ចផង របស់ អ្នកដឹកនាំ មានការប្រុងប្រយ័ត្ន។ ការ ការពារនេះ គឺ ឋិតនៅលើ បង្កើត ឱ្យមាន សង្គ្រាម គ្នាឯង នៅ ស្រុកខ្មែរ រវាង ព្រះចន្ទរាជា នឹង ស្តេចកន ដើម្បីបន្ថយ សក្តានុពល របស់ខ្មែរ។ ល្បិច របស់ ព្រះចៅសៀម ផ្តល់ កងទ័ព មាន រេហ៍ពល ៥ ពាន់នាក់ និង ដំរី ១ ពាន់ក្បាល និង ប្រគល់ ដាវ អាជ្ញាសឹក ដល់ ព្រះចន្ទរាជា សំរាប់ ឱ្យទៅចាប់ដំរីស, ប៉ុន្តែ ស្តេចខ្មែរ បែរជា ធ្វើផ្ទុយពី ព្រះរាជបញ្ជា ទៅវិញ, វា នឹងអាចទុក ជា ក្រឡេច មិនអាចឱ្យ ស្តេចកន ចោទព្រះអង្គ ថា ជ្រៀតជ្រែក ចូលក្នុងកិច្ចការ ផ្ទៃក្នុងខ្មែរ នោះបានឡើយ។ មួយវិញទៀត សង្គ្រាម គ្នាឯងនេះ ទោះបី ខាងណាមួយឈ្នះ ក៏សៀម មាន ផលប្រយោជន៍ ជានិច្ច ព្រោះ ស្រុកខ្មែរ នឹងចុះអន់ថយ គ្រប់វិស័យ គឺ សេដ្ឋកិច្ច, យោធា និង កម្លាំងជាតិ បន្ទាប់ពីសង្គ្រាម។ ដូច្នេះ ស្រុកខ្មែរ នឹងក្លាយ ជា សត្វចំណី (proie) សំរាប់ សៀម ងាយចាប់ស៊ី។ សួរថា តើ ព្រះចន្ទរាជា ដឹង អំពី ផលអវិជ្ជមាន នេះដែរឬទេ? ទ្រង់ ពិត ជាដឹង តែ ទ្រង់ ត្រូវការ ជំនួយសៀម ជាការចាំបាច់ សំរាប់វិលត្រឡប់ មកធ្វើសង្គ្រាមនឹងស្តេចកន ព្រោះបើ វិលត្រឡប់ ដោយដៃទទេ គឺពិតជា ពុំអាច បញ្ចុះបញ្ចូល ប្រជារាស្ត្រខ្មែរ រួមទាំង តាមឿង និង ចៅហ្វាយខេត្ត បាត់ដំបង ឱ្យចូលរួម

---

26 សមគ្គចេតនា : គំនិតព្រមព្រៀង។

# សង្គ្រាម គ្នាឯង

ក្នុងបុព្វហេតុ របស់ព្រះអង្គ បានងាយស្រួល នោះឡើយ។ ដូច្នេះ ជំនួយ របស់សៀម មាន អភិ[27]អនុភាព ពីដំបូងទី ព្រោះ បើក ឱកាសឱ្យ ព្រះចន្ទរាជា មាន មូលដ្ឋាន នៃ ភាពជឿជាក់ ពី សំណាក់ អនុជីវិន[28] ដ្បិត យល់ឃើញថា ព្រះអង្គ មានសៀម នៅ ពីក្រោយ ដែល នឹងអាច តស៊ូ ប្រឆាំងនឹង ស្តេចកន ដែល កំពុងមាន បារមី។ បច្ចុគ្គមន៍[29] ចំពោះ ព្រះអង្គ ពីសំណាក់ ម ន្ត្រីខ្មែរ មួយចំនួន ដែលនៅស្មោះនឹង រាជវង្ស ពេញសិទ្ធិ និង ប្រជារាស្ត្រ ខាងកើត ដែល នៅកោតខ្លាច បារមី ស្តេចសៀម នៅឡើយ តាំងពីរាជ្យ ព្រះធម្មរាជា[30] (១៤៧៨-១៥០៤) ដែល ព្រះ អង្គ ដាក់ ស្រុកខ្មែរ ជា អនុប្រទេស របស់សៀម ព្រោះ ស្តេ ចសៀម បានជួយព្រះអង្គ ឱ្យបានឡើងគ្រងរាជសម្បត្តិ វា អាស្រ័យ ច្រើន លើ ជំនួយសៀមនោះឯង។ ប៉ុន្តែ ព្រះចន្ទរាជា ព្រះអង្គ ជា ស្តេច មាន ទេពកោសល្យ ចេះឆ្នៃ ជំនួយបរទេស មាន លក្ខណៈ ជា និមិត្តរូប ច្រើនជាង ជា សម្ភារៈ ឱ្យទៅជា បុព្វ ហេតុជាតិ ដែលជាកត្តាចម នៃជ័យជំនះព្រះអង្គលើ ស្តេចកន។

27 អភិ : ប្រើក្នុងន័យ ក្រៃ, ក្រៃលែង, ក្រៃពេក។
28 អនុជីវិន : អ្នកធ្វើការបំរើ។
29 បច្ចុគ្គមន៍ : ការក្រោកទទួល, ការតាមជូនដំណើរ។
30 ព្រះធម្មរាជា ទ្រង់ មាន មាតា ជា ជាតិសៀម។ ព្រះអង្គ ត្រូវជា បិតា របស់ព្រះចន្ទរាជា។

# សង្គ្រាម គ្នាឯង

## អត្ថាធិប្បាយ

ចូលមកដល់ទឹកដីខ្មែរ ព្រះចន្ទរាជា បញ្ចុះបញ្ចូល អាណាប្រជានុរាស្ត្រ តាំងពីប្រទេសដែនមក ផ្សំគ្នាជា ២ពាន់ នាក់ ហើយ លើកទ័ព ខ្មែរ-សៀម ចូលវាយបន្ទាយ ខែត្រសៀមរាប បែក ហើយព្រះអង្គ យាងចូល ទៅក្នុង បន្ទាយ មហានគរ។ បន្ទាប់មក ព្រះអង្គ ទទួលជំនួយ លួសលុប ពីសំណាក់ តាមឿង ដ្បិត នរនេះ នាំបក្សពួកខ្លួន ទៅ សម្លាប់ ចៅហ្វាយ ខែត្រ ពោធិសាត់ ខាងស្តេចកន ហើយ បញ្ចុះបញ្ចូល ទ័ព រក្សាខេត្តនេះ និង ប្រជារាស្ត្រ ឱ្យចុះចូល ព្រះអង្គ បានទាំងអស់។ ក្រោយមក តាមឿង ស្លាប់ដោយ ជួយយក អាសា ព្រះអង្គ ដែល នាំឱ្យ ទ្រង់ វាយ កងទ័ពធំ ស្តេចកន បែក ដឹកនាំដោយ ចៅហ្វា កៅ ជា មា របស់នរនេះ។ ជ័យជំនះ បើកផ្លូវឱ្យ ព្រះចន្ទរាជា នាំទ័ព ចូលទៅ ទិសខាងលិច ដែល ជា ដែនដីអំណាច (fief) របស់ស្តេចកន។ លុះលើកទ័ព ចេញ ពីខែត្រ អម្រិន្ទបូរ មកដល់ ខែត្រ កំពង់ឆ្នាំង ព្រះអង្គ ជួបប្រទះ ជា ថ្មី ទ័ព ចៅហ្វាកៅ ហើយ ទ័ពទាំងសងខាងចូលច្បាំគ្នា តតរូញរា។ ខណៈនោះ មាន អភូតហេតុមួយ គួរឱ្យអស្ចារ្យណាស់ គឺ ដំរីភ្លុកមួយ ជា ឧត្តមជំណាស់ របស់ ចៅពញាកៅ វាផ្អើល រត់ទៅព្រៃចដំបូកមួយ រលើងរលំទាំងដើមឈើរមៀលទៅលើ កងទ័ពខ្លួនឯង បែកទាំងសំបុកឧម៉ាល់ ហើយហើរទៅទិចកងទ័ព។ រហ៏ពល ខាង កៅ ទ្រាំនឹង ឧម៉ាល់ ព្រលួតល័ខ ពុំបាន ក៏រត់ខ្ចាត់ខ្ចាយ បែកទ័ពទៅ។ ព្រះចន្ទរាជា ក៏

# សង្គ្រាម គ្នាឯង

ដេញតាមទាន់ កៅ, ទ្រង់ ចូលតយុទ្ធនឹងសត្រូវ ជាបន្ទាន់។ លុះប្រយុទ្ធគ្នា មិនបានប៉ុន្មានភ្លេងផង ព្រះចន្ទរាជា ក៏កាប់ត្រូវស្មា កៅ មានពិការ ជាទម្ងន់ តែ ត្រូវបាន សេនាទាហាន ជួយការពារ នាំរត់រួច ទាំង ចៅហ្វាយ និង កងទ័ព។ វាយទ័ពសត្រូវបែក ព្រះចន្ទរាជា ទ្រង់លើកទ័ព ចូលទៅបោះទ័ព នៅខាងលិចភូមិរលាប្អៀ ក្នុង ខែត្រកំពង់ឆ្នាំង។ កាលដឹងថា ព្រះចន្ទរាជា មកបោះទ័ព នៅ ខែត្រ រលាប្អៀ ចៅហ្វាយ ខែត្រ លង្វែក ខាងស្តេចកន ក៏ប្រកាស ថ្វាយខ្លួន ចូលទៅបំរើ ព្រះចន្ទរាជា វិញថែម ទាំងនាំ រាស្ត្រប្រជា និង បណ្ណាការ យកទៅថ្វាយព្រះអង្គផង ជា ជំនួយសឹក។ បរាជ័យ ផ្ទួនៗ នោះ នាំឱ្យ ស្តេចកន មានវិតក្កទុក្ខទោមនស្សណាស់ រហូត ដល់ទៅ ទ្រហោយំ។ ដើម្បី តទទឹងនឹងទ័ព ព្រះចន្ទរាជា, ស្តេចកន រៀបចំ យុទ្ធសាស្ត្រ ជាថ្មី គឺប្រមូលទ័ព មក បោះទ័ព នៅ បន្ទាយភ្នំពេញ។ បន្ទាប់មក ស្តេចកន បញ្ជា រេហ៏ពល ឱ្យវាយចូល បន្ទាយលង្វែក ដែល មានចៅហ្វាយខែត្រ ក្បត់នឹងខ្លួន។ លុះដឹងដំណឹងនេះ ព្រះចន្ទរាជា ឱ្យសេនាសេះ នាំ សារ ទៅប្រាប់ នាយទ័ព ការពារបន្ទាយ លង្វែង ថា ឱ្យធ្វើជាចាញ់ ហើយ នាំរេហ៏ពល រត់មកទិសខាងជើងទៅ, នៅទីនោះ ព្រះអង្គ រៀបចំ លាក់ទ័ព (embuscade) មាន ទាំងកាំភ្លើងធំ។ ចាញ់ឧបាយកលព្រះចន្ទរាជា, ចៅពញាយមរាជ ជានាយទ័ព ខាងស្តេចកន ក៏ប្រញាប់លើកទ័ពដេញតាម សត្រូវ។ មកដល់ កន្លែង បង្កប់ទ័ព ព្រះចន្ទរាជា ក៏បញ្ជា ឱ្យរេហ៏ពល វាយផ្ទប់ សម្លាប់ កងទ័ពសត្រូវ ពីក្រោយ ដោយទ័ពសត្រូវពុំដឹង

ខ្លួន។ ចៅពញាយមរាជ និង នាយទ័ព ១០ នាក់ទៀត ខាង ស្ដេចកន ត្រូវបាន ទ័ព ព្រះចន្ទរាជាចាប់ខ្លួនបាន។ ស្ដេចខ្មែរ ក៏បញ្ជាឱ្យ កាត់ក្បាល ចៅពញាយមរាជ និង នាយទ័ពទាំង ១០ នាក់ ទៀត។ បន្ទាប់មក ទ្រង់ បញ្ជាឱ្យ ចៀរស្លឹកត្រចៀក មេកង ១០ នាក់ ហើយ ឱ្យនាំ ១១ ក្បាល ទៅឱ្យ ស្ដេចកន ហើយ ផ្ដាំ ជាសំដីសឹកថា៖ ‹‹បើ វា អាង ពលច្រើន ឱ្យលើកមកទៀត ឬ បើ យល់ថា ភ្លៀងធ្លាក់ហើយ ជិតរដូវល្មមនឹងរាស្ដ្រ ធ្វើស្រែចំការ ហើយ នឹងចង់ ឈប់ច្បាំង ឱ្យរាស្ដ្រធ្វើស្រែសិន ក៏តាមចិត្តវាចុះ››។ ស្ដេចកន យល់ព្រម តាមសំណើរ របស់ ព្រះចន្ទរាជា ស្រប តាម សុភាបុរាណថា ‹‹ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ›› ក៏បញ្ជូន ទូត និង អនុទូត នាំសារ ទៅថ្វាយ ព្រះអង្គ។ នៅក្នុងសារនោះ ស្ដេចកន ប្រើ ពាក្យ ‹‹អ្នកអូន›› ចំពោះ ព្រះចន្ទរាជា។ លុះអាល័ក្ស ថ្លែង សារនោះ ចប់ហើយ, ព្រះចន្ទរាជា ទ្រង់ ព្រះពិរោធខ្លាំងណាស់ ទ្រង់ត្រាស់ថា៖ ‹‹អារាជទូត វិលទៅ ប្រាប់ម្ចាស់ឯងចុះ ថា អញ ព្រមសម្រាក ឱ្យរាស្ដ្រធ្វើស្រែ តែថា អញ សុំកុំឱ្យ ម្ចាស់ឯងថា ជា បង ជា ប្អូន ឡើយ ដ្បិតម្ចាស់ឯងនឹងអញនេះ មាន ជាតិត្រកូល ឆ្ងាយពីគ្នាណាស់››។

មកដល់ឆ្នាំ ១៥១៦ ព្រះចន្ទរាជា វាយរំដោះបាន ខែត្រតូចធំ ចំនួន ១២ ឬ ១៣ ខែត្រ។ ចំពោះព្រះអង្គ ក្រឡាផ្ទៃដីនោះ វា ល្មមទុក ជា ទីសំណាក់ និង មូលដ្ឋានយោធា បានហើយ, ដូច្នេះ បើ ផ្អាក សង្គ្រាម មួយ រដូវ ឱ្យរាស្ដ្រធ្វើស្រែ ក៏ វា មិនធ្វើឱ្យមានគ្រោះ

## សង្គ្រាម ភ្នាក់ងារ

ថ្នាក់ ដល់យុទ្ធសាស្ត្រ យោធា និង នយោបាយ, ផ្ទុយទៅវិញ វា ជា ឱកាស សំរាប់ ទៅបញ្ចុះបញ្ចូល លួងចិត្ត ចៅហ្វាយស្រុក នៃ ខែត្រ ដែលនៅក្រោម ផែនដី ស្តេចកន ឱ្យបែរក្បត់ នរនោះ មកចូលខាងព្រះអង្គ វិញ ហើយ ក៏ មាន ពេលវេលា ហ្វឹកហ្វឺន ទ័ព និង ជ្រើសរើស នាយកង នាយក្រុម និង នាយពល តាម ការប្រឡងថ្វីដៃ របស់ បេក្ខជន។

ចៅហ្វាយខែត្រអាសន្នុក ខាងស្តេចកន ដឹងថា ព្រះចន្ទរាជា វាយឈ្នះ ទ័ពយោមរាជ ហើយ កាត់ក្បាលនរនេះ ហើយឥឡូវ ទ្រង់ នាំទ័ពហ្លួង ឆ្លងទន្លេ វិលត្រឡប់ ទៅបន្ទាយ ខែត្រអមរិន្ទ បូរ វិញ ក៏តាំង កេណ្ឌកងទ័ព នៅពេល រយៈពេល ផ្អាកសង្គ្រាម គ្រប់ស្រុក ២៦ ដែលនៅក្រោម អាជ្ញាធរខ្លួន គឺ មឿងជីក្រែង, ស្ទោង, ព្រំទេព, ព្រៃក្ដី, ក្រកោះ, កំពង់ស្វាយ, កំពង់ហាវ, ប្រាសាទ១០, កោះកែ, ស្វាយរលែក, គោកសេះ, សែន, កំពូល ពេជ្រ, មឿងពោធិរោង, ត្រឡែងកែង, ងន, ឈើទាល, ស្រដៃ, សារនគរ, ស្រយូវ, ម្លូព្រៃ, ព្រៃក្ដី, សៀមបូក, សៀមប៉ាង, ព្រះប្រស ប បាន ចំនួណ ៨ ម៉ឺននាក់។ លុះចប់ រដូវរាស្ត្រធ្វើស្រែ ក៏លើក កងទ័ពនោះ ឆ្លងទន្លេ ទៅខែត្រក្រគរ ដើម្បី វាយផ្ទប់ ទ័ព របស់ ព្រះចន្ទរាជា។ ព្រះចន្ទរាជា ដឹង ថា ចៅពញាឱទ័យធិរាជ ចៅហ្វាយស្រុក អាសន្នទុក្ខ ខាងសត្រូវ កំពុង រៀបចំ ចម្លង កងទ័ព មកមាត់ព្រៃទន្លេសាប មកត្រើយខាងកើត, ទ្រង់ ត្រាស់បញ្ជាឱ្យ ចៅពញាយសរាជា ជា ក្មួយ ដែល នៅថែរក្សា

## មេគ្រាម ភ្នាងឯខ

ខែត្រពោធិសាត់ ឱ្យលើកទ័ព ១ ម៉ឺននាក់ កាន់កាំភ្លើងធំតូច ទៅបង្កប់ចាំ នៅកំពង់ដែនទន្លេសាប ហើយ បើឃើញ ទ័ពសត្រូវ ត្រូវវាយបាច់កាំភ្លើង ទាំងធំតូច កុំឱ្យវា ឡើងគោកបាន ជាដាច់ខាត។ ព្រះអង្គ ត្រាស់បញ្ជាផងដែរ ចៅពញាយោធាសង្គ្រាម ពៅ នាំរេហ៍ពល ២ ម៉ឺននាក់ នៅមាត់ព្រែកទន្លសាប ត្រើយខាងកើត ហើយទ្រង់ផ្តាំថា ‹‹បើឮសូរកាំភ្លើងសន្យាទ័ព ហើយ ឱ្យលើកទ័ពចូលច្បាំងឱ្យបានសម្រេចចុះ››។ ចំណែក ព្រះអង្គ វិញ ទ្រង់ ដឹកនាំ កងទ័ពជើងទឹក មាន ទូកចម្បាំង ២៥ គ្រឿងទៅបង្កប់ចាំស្ទាក់នៅព្រែកមាត់ទន្លេសាបចាំទ័ពសត្រូវ។ ចាំមិនយូរប៉ុន្មាន ក៏ស្រាប់តែឃើញ ក្បួនទូកសត្រូវ អុំចូលមកក្នុង បរិវេណ គ្រងទុក, ព្រះចៅពញាយសរាជ ក៏ត្រាស់បញ្ជា ឱ្យរេហ៍ពល បាញ់កាំភ្លើងធំតូច ទៅលើទូកសត្រូវ ដើម្បី ខាយាំង កុំឱ្យមកជិតជ្រាំងបាន។ កងទ័ព ចៅពញាឧទ័យធិរាជ ខាង ស្តេចកន ជិះទូកកំណែន គ្មានចំណាប់នឹងបាញ់តវិញ ក៏បែកកងទ័ព នាំគ្នាអុំរត់គេច ពី ដែនបាញ់ របស់ទ័ពសត្រូវ តាមផ្លូវទឹក ដែល ព្រះចន្ទរាជា ទ្រង់ បើកផ្លូវ ឱ្យរត់។ រត់ឡើងគោកបាន ក៏នាំគ្នាទៅពួន ក្នុងព្រៃ ដោយ នឹងស្មានថា បានរួចខ្លួន តែនៅទីនោះ កងទ័ព ចៅពញាយោធាសង្គ្រាម ដែលបង្កប់ខ្លួនចាំ ក៏ទទួលបាញ់ កាប់ចាក់ កងទ័ពសត្រូវ ឥតត្រាប្រណីឡើយ។ ទ្រាំពុំបាន ក៏នាំគ្នារត់ឆ្លង ទៅត្រើយខាងកើតវិញ។ ចំណែក មេទ័ពខាងស្តេចកន និង នាយទ័ព ជា ចៅមឿង ១០ នាក់ ត្រូវបានកងទ័ពទឹក របស់ ព្រះចន្ទរាជា ចាប់ខ្លួនបាន។ ១១ នាក់ទៀត

# សង្គ្រាម ត្រាំងឯក

ត្រូវបាន កងទ័ព ចៅពញាយោធាសង្គ្រាម ចាប់ខ្លួនបានដែរ ហើយ ដាក់ក្តីប្រចាំការ តម្រាំ ព្រះចន្ទរាជា យាងទៅដល់។ រេហ៍ពល ខាង ស្តេចកន ចំនួន ៦ ម៉ឺននាក់ និង ចៅមឿង ចៅបាន នាយសេនាទាហាន ឯក ទោ ត្រី ដែល មិនស្លាប់ក្នុង សមរភូមិ ក៏នាំគ្នា សន្មត់សញ្ញា សូមចូលខ្លួន បំរើ ព្រះចន្ទរាជា វិញ។ ទ្រង់ អនុញ្ញាតឱ្យតាមសុំ។ ទ្រង់ ត្រាស់បញ្ជា ឱ្យអ្នកទាំងនោះធ្វើសច្ចាប្រណិធាន ភ្លាម មិនចាំបាច់មាន ក្រុមព្រះបុរោហិត ជាអ្នកវិធីការ ដោយ ថា តាមព្រះអង្គ ៣ដងម្នាក់ ថាមិន ក្បត់នឹងព្រះអង្គ ផ្ទុយទៅវិញ នឹងត្រូវស្លាប់ ដោយចាញ់នឹងសប្បថ។ សុំចុះចូលអស់ហើយ ព្រះចន្ទរាជា ត្រាស់បង្គាប់ឱ្យ ចៅពញាឱទ័យរាជ ចៅហ្វាយស្រុកអាសន្នទុក្ខ ដែលទើបនឹងចុះចូល នាំកងទ័ព របស់ខ្លួន ទៅវាយបន្ទាយ ខែត្រ កំពង់សៀម, ជើងព្រៃ និងស្ទឹងត្រង់។ ដោយ ខ្លួន ធ្លាប់ខ្លាចថ្វីដៃ ចៅហ្វាយចាស់ ចៅមឿងទាំង៣ខែត្រនោះ ដឹងថា ចៅពញាឱទ័យធិរាជ ចុះចូលសត្រូវ ហើយលើកកងទ័ព មកវាយបន្ទាយខ្លួន ក៏នាំគ្នា ចុះទូករត់ទៅក្រុងស្រឡប់ពិជ័យ ព្រៃនគរ។

កាលដឹងដំណឹង ថា ស្តេច វង្សរាជ្យពិត យាងត្រឡប់ ពីស្រុកសៀម ច្បាំងឈ្នះ ស្តេចកន ហើយ ត្រួតត្រា ព្រះនគរ ជាងពាក់កណ្តាល ព្រះសង្ឃ រាជាគណៈ, ឋានានុក្រម និង ព្រះបុរោហិតព្រឹទ្ធាចារ្យ, ព្រះរាជវង្សានុវង្ស ដែលនាំគ្នារត់ខ្ចាត់ខ្ចាយ ចេញពីទីស្រុកភ្នំពេញ និង ក្រុងបាសាន ព្រោះ ព្រះស្រីសុគន្ធបទ ធ្វើ ស

ង្គ្រាម ចាញ់ ស្ដេចកន ក៏នាំគ្នាចេញពីព្រៃ ដែលពួនជ្រកនោះ មកជួបនាយកងទ័ព សុំឱ្យនាំខ្លួន យកទៅថ្វាយ ព្រះចន្ទរាជា ជា ខ្ញុំរាជាការ។ បន្ទាប់មក ក្រុម វណ្ណៈអភិជន ទាំងនោះឯង បានស្នើសុំឱ្យ ព្រះចន្ទរាជា រៀបព្រះរាជពិធី ជា សង្គ្រាមមាភិសេក[31] ថ្វាយជា សុវត្ថិមង្គល ដើម្បី ឱ្យមាន រាជបារមី ខ្ពស់ជាង ស្ដេចកន ជា រាជ្យភង្គ។ ត្រូវនឹងព្រះហឫទ័យផង ព្រះអង្គ ក៏យល់ព្រមតាមសំណើរនោះទៅ។ នៅឆ្នាំ ១៥១៦ ព្រះចន្ទរាជា ព្រះអង្គ ទ្រង់គ្រឿង មាហាខត្តិយាធិខិន ទ្រង់ ធ្វើព្រះរាជដំណើរ ចូលក្នុង រោងរាជពិធី មានព្រះគ្រូ ថ្វាយមហាស្វេតច្ឆ័ត្រ, ស្ដេច ឋិតនៅនាបូព៌ា ពីមុខស្វេតច្ឆ័ត្រ ទើប ព្រះរាជវង្សានុវង្ស សេនាមុខមន្ត្រី ក្រាបថ្វាយព្រះរាជមង្គល ព្រះពិធីពរជ័យ ជា ស្ដេចគ្រងរាជសម្បត្តិ នៅ ក្រុងកម្ពុជាធិបតី មានព្រះនាមរាជ ជា ‹‹ សម្ដេច ព្រះបរមរាជា ចន្ទរាជា គ្រងក្រុងកម្ពុជាធិបតី››។ ព្រះអង្គ ប្ដូរ ឈ្មោះ ខែត្រ អមរគិរិបូរ ឬ អម្រិន្ទបូរ ដែល ព្រះអង្គកំពុងគង់នៅ ឱ្យហៅថា ‹‹ខែត្របរិបូណ៌›› វិញ។

នេះនឹងនិយាយ អំពី ស្ដេចកន។ លុះដឹងថា ព្រះចន្ទរាជា ធ្វើ សង្គ្រាមមាភិសេក ក៏មានចិត្តក្ដៅក្រហាយ ក៏ចេញសំបុត្រ ប្រាប់

---

[31] ប្រាប្តាភិសេក ជា ពាក្យសំស្ក្រឹត ប្រែថា ‹‹ដែលមានអភិសេកប្រាកដហើយ›› បានន័យថា អភិសេក ព្រះមហាក្សត្រ ដែលបានបង្ក្រាបអរិន្ទរាជសត្រូវ ហើយឡើងសោយរាជ្យ។ អភិសេក ព្រះមហាក្សត្រ ដែល ពុំទាន់បានធ្វើសង្គ្រាម មិននឹងសោយរាជ្យទេ ច្បាប់ឱ្យហៅថា មុន្ទាភិសេក ឬ រាជាភិសេក។ ៦ សង្គ្រាមមាភិសេក គឺ អភិសេក ក្នុងពេលកំពុងធ្វើសង្គ្រាម។

# សង្គ្រាម ខ្លាងឯង

ទៅ ចៅហ្វាយស្រុក ចៅមឿង ចៅបាន ត្រួតត្រា អាណាខេត្រ ឡើង (ខេត្រឡើង គឺ ខេត្រជាចំណុះ) ឱ្យកេណ្ឌកងទ័ព បាន ចំនួន ១សែន ២ម៉ឺននាក់។ បង្ហាត់បង្រៀន រេហ៍ពល ឱ្យចេះ កាន់អាវុធស្ទាត់ តាមក្បួតពិជ័យសង្គ្រាម ក៏បង្គាប់ឱ្យ ចៅពញា លំពាំង ចៅពញាស្រោល ឱ្យយុំកងទ័ព ២ម៉ឺននាក់ ឆ្លង ទៅតាំង ទ័ព នៅខេត្រ សម្រោងទង, ឱ្យ សម្ដេចចៅហ្វា កៅ ជា មា យុំ ពល ៣ម៉ឺននាក់ ទៅតាំងទ័ព នៅបន្ទាយភ្នំពេញ។ ព្រះចន្ទរាជា ទ្រង់ដឹងថា សត្រូវ ធ្វើ ចរភាពទ័ព ព្រះអង្គ ប្រាប់ ឧកញ៉ាចក្រី និង វង្សាអគ្គរាជ ឱ្យយុំពល ២ម៉ឺននាក់ លើក ទៅពាំងមុខ សត្រូវ, ចំណែក ព្រះអង្គ ទ្រង់ នាំរេហ៍ពល ៣ម៉ឺននាក់ លើកទៅ តាំងនៅ ភូមិជ័យសួគ៌ នៅខេត្រលង្វែក រង់ចាំស្ដាប់រាជាការស ង្គ្រាម, បើឃើញកុន ទ្រង់នឹងលើកទៅជួយជាឆាប់។ ខណៈនោះ កងទ័ព សេនាទាហាន រេហ៍ពល ទាំងសងខាង ចូលប្រយុទ្ធគ្នា ដោយមារុំផខ្លី ជា សន្ទឹក គិកកង កោលហល។ ពេលនោះ កង ដំរី ១៤០ ក្បាល របស់ ព្រះចន្ទរាជា ដឹកនាំដោយ ឧកញ៉ា នរិ ន្ទនាយក លើកចេញពីព្រៃ វាងបាន ទៅពីក្រោយ ទ័ពសត្រូវ ហើយ ក៏បរចូល ទៅរួសរាន់ជាន់ ជល់ពង្រាបពីក្រោយកងទ័ព នាំឱ្យ សត្រូវទ្រាំពុំបាន ក៏បែកទ័ព រត់ទៅ បន្ទាយភ្នំពេញវិញ។ ឃើញដូច្នេះ, មេទ័ព ខាងអ្នកឈ្នះ ក៏លើករហូតទៅវាយបាន បន្ទាយខ្ទាំងនៅ ខេត្រ បាទី, ទ្រាំង ចាប់បានខ្លួន ចៅហ្វាយ បាទី, ចៅមឿងព្រៃកប្បាស, កណ្ដាលស្ទឹង, គងពិសី, ភ្នំស្រួច, បន្ទាយមាស, ពាម, ស្រែរនោង, កញ្ចុំ នាំមកក្រាបទូលថ្វាយព្រះ

## សង្គ្រាម ត្បាងខ

ចន្ទរាជា។ ព្រះអង្គ អនុគ្រោះ លើកលែងខ្លួន អ្នកទាំងនោះ និង ចាត់ឱ្យ ទទួលទាន ទឹក ព្រះពិភ័ទ្ធសច្ចា ហើយ ឱ្យទៅ រក្សាស្រុក ខែត្រដូចដែលវិញ។

លុះរួចបុណ្យ អកអំបុក ព្រះចន្ទរាជា ត្រាស់បង្គាប់ឱ្យ ឧកញ៉ា កែវ, កៃ និង គាំ លើកទ័ព ទៅវាយ បន្ទាយភ្នំពេញ។ នាយទ័ព ផែនដីខាងកើត កៅ, លំពាំង, ស្រាល, ចៅហ្វាយស្រុកសំរោង ទង និង ភ្នំពេញ ចេញទទួលច្បាំង ជួនឈ្នះ ជួនចាញ់ ម្ដងម្នាក់ ជា ច្រើនដង រហូត ដល់ រដូវ រាស្ត្រធ្វើស្រែ ក៏ឈប់ច្បាំងគ្នាសិន។ លុះផុតវេលា រាស្ត្រធ្វើស្រែ, ព្រះចន្ទរាជា ចាប់ផ្ដើម វាយលុក ជាថ្មី ផែនដីខាងកើត។ លើកនេះ ព្រះចន្ទរាជា ប្រើល្បិច ធ្វើជាចាញ់ ដោយរៀបចំ បង្កប់ទ័ព ទាំងជើងទឹក និង គោក ចាំវាយសត្រូវ ដែលដេញតាមវាយទ័ពដកថយ។ ចៅហ្វា កៅ មេកងទ័ពធំ របស់ ស្ដេចកន ឃើញ រេហ៍ពលសត្រូវ រត់ចេញពីសមរភូមិ ក៏នឹង ក្នុងចិត្តថា ស្ដេច ចន្ទរាជា អស់បុណ្យហើយ ក៏លើកកងទ័ពធំ ដេញតាមសត្រូវ ទុកឱ្យ នាយទ័ព លំពាំង និង ស្រាល ការពារ បន្ទាយភ្នំពេញ ជាមួយរេហ៍ពល មួយកងតូចប៉ុណ្ណោះ។ កៅ មាន ជំនឿងប់ថា លើកនេះនឹងទទួលជ័យជំនះ ជា ស្ថាពរ លើ កងទ័ព ត្រើយខាងលិច។ តែ ការស្រមៃនោះ វា មានរយះពេល ដ៏ខ្លី ព្រោះ កងពលប្រដេញ របស់ខ្លួន ជួបការវាយឆ្មក់ នៃសត្រូវ គ្រប់ផ្លូវ រត់ ជានុយ ឱ្យដេញតាម។ សូម្បី ទព័ទូក របស់ ចៅហ្វា កៅ ក៏ជួបការវាយប្រហារ នៅព្រែកតាទែន ពីសំណាក់ទ័ពឆ្មក់

## សង្គ្រាម ត្រាងខ

សត្រូវ ពីក្រោយផង ពីមុខផង, រវេហ៍ពលទ្រាំពុំបាន ខ្លះក៏លោតទឹក ហែលរត់ ខ្លះក៏ត្រូវស្លាប់នឹងអាវុធ, ខ្លះក៏លង់ទឹកស្លាប់ដោយមិនចេះហែលទឹក, ចំណែក ចៅហ្វា កៅ ខ្លួនឯងវិញលោតទឹកទន្លេ ហែលរត់ ត្រាតែរួច មកដល់ក្រុងបាសាន។ ដូច្នេះ វាសនា នៃ បន្ទាយភ្នំពេញ វានឹងជួប បរាជ័យ ព្រោះ នាយទ័ព លំពាំង និង ស្រាល ពុំអាច ទ្រាំនឹង ការវាយប្រហារសត្រូវយ៉ាងសាហាវ ក៏នាំគ្នា រត់ចោលបន្ទាយ តែត្រូវ មេទ័ពហ្លួង ខាងលិច សម្លាប់បានទាំងពីរនាក់នោះទៅ។ ព្រះចន្ទរាជា ឈ្នះសង្គ្រាមក្នុងគ្រានេះ យកបាន ខែត្រ ភ្នំពេញ, សំរោងទង, បាទី, ទ្រាំ, កំពត, កំពង់សោម។ តែ នៅ ខែត្រ បាសាក់, ព្រះត្រពាំង, ក្រមួនស, ឱម៉ៅ នៅក្រោម មេទ័ព ស្តេចកន គឺ ចៅពញាពិស្ណុលោក លោក បានតាំងបន្ទាយ រឹងមាំនៅឡើយ។

នៅឆ្នាំ ១៥១៩, ស្តេចកន ប្រើល្បិចថាស់ គឺ ឱ្យទាហាន ១០១ នាក់ ឱ្យក្លែងរត់ចូល ទៅខាង ស្តេច ចន្ទរាជា។ បើបានសម្រេចដូចគ្រោងទុក ឱ្យនាំគ្នាលុកសម្លាប់ ស្តេចសត្រូវនោះទៅ។ ព្រះចន្ទរាជា យល់ព្រមទទួល រវេហ៍ពល ទាំងនោះ ព្រោះ ព្រះអង្គធ្លាប់ប្រកាស ថា ទ្រង់ លើកលែងទោស អស់ខ្ញុំរាជាការ របស់ ស្តេចកន ដែល រត់ចូល មក បំរើ ទ្រង់វិញ។ ថ្ងៃមួយ ព្រះចន្ទរាជាទ្រង់ចុះស្រង់ ក្នុងទឹកស្ទឹង នៅខែត្របរិបូណ៌ ព្រមទាំងសេនាទាហានស្និទ្ធព្រះអង្គជាច្រើន។ គ្រប់គ្នា ផ្លាស់សំពត់ ចុះងូតទឹក, វៀរលែងតែ ទាហាន ១០១ នាក់ ដែល មកចុះចូលនឹងព្រះអង្គ

## សង្គ្រាម គ្នាឯង

ចុះងូតទឹកទាំងសំពត់ ព្រោះ អាចលាក់អាវុធបាន។ ព្រះចន្ទរាជា ទតឃើញដូច្នេះ ក៏បង្គាប់ឱ្យ នរទាំងនោះផ្លាស់សំពត់ឱ្យអស់គ្រប់គ្នា។ ពួកទាំងនោះ យល់ថា មុខជាពុំរួចខ្លួនទេ ក៏ថ្លស់ទឹកមុខគ្រប់ៗគ្នា។ ព្រះចន្ទរាជា ទ្រង់រិតតែសង្ស័យ ក៏ស្ទុះឡើងពីក្នុងស្ទឹង ទៅប្រថាប់ក្រោមម្លប់ឈើមួយ។ ទ្រង់ចាប់ព្រះសែងដាវទាំងស្រោម, រំពេចនោះ ពួកក្បត់ ក៏ស្ទុះឡើងពីស្ទឹង ហូតកាំបិតពីភ្លៅ នាំគ្នារត់សំដៅ ទៅរកព្រះចន្ទរាជា ដើម្បី ប្រហារព្រះអង្គ តែ ទ្រង់ ស្ទុះទៅត កាប់ត្រូវ មេ ពួកក្បត់នោះ។ រីឯ ខ្ញុំរាជាការ ដែលតាមហែ ក៏ផ្អើលឆោឡោឡើង, ខ្លះចូលប្រយុទ្ធដោយដៃទទេ, ខ្លះទៀត ស្ទុះទៅដកបង្គោលរបង ចូលតទឹងពួកក្បត់។ ពួកក្បត់ ស្លាប់ខ្លះ នឹងត្រូវចាប់ ៣៥ នាក់ ខ្លះទៀតរត់រួច។ ព្រះចន្ទរាជា ទ្រង់ត្រាស់ឱ្យកាត់ក្បាល ពួកក្បត់ ហើយដោត ជាបម្រាម។

ស្ដេចកន យល់ថា បើទុកឱ្យ ព្រះចន្ទរាជា ទ្រង់គង់នៅសុខក្សេមក្សាន្ត ច្បាស់ ជា ទ្រង់ មាន ពេលវេលា គ្រប់គ្រាប់នឹងពង្រឹង ផែនដីត្រើយខាងលិច ឱ្យរឹតតែមាំមួនទៀត ជាពុំខានហើយ នាយកងទ័ព របស់ខ្លួន ចេះតែចាញ់ឧបាយកល ស្ដេចនេះទៀត។ ដូច្នេះ ស្ដេចកន ក៏កេណ្ឌកងទ័ពបាន ៨ម៉ឺននាក់លើកមកច្បាំងនឹងព្រះចន្ទរាជា។ លើកនេះ ស្ដេចកន ដឹកនាំទ័ព ដោយខ្លួនឯង ទុកឱ្យ ចៅហ្វា កៅ នៅការពារ ក្រុងស្រឡប់ពិជ័យព្រៃនគរ ដ្បិត មា នៅមានរបួសចិត្ត ដោយសារ ច្បាំង

# សង្គ្រាម ក្លាឯង

ចាញ់សត្រូវ។ កងទ័ពជើងទឹក មានទូកចម្បាំង ៣០០ ទូក មកតាំង ជលមូលដ្ឋានទ័ព នៅកំពង់ព្រៃកពោធិ, ចំណែក ទ័ពហ្លួងខាងកើត មកបោះទ័ព នៅភូមិឃ្លុង ក្នុងខែត្រត្បូងឃ្មុំ។ បន្ទាប់មក ស្តេចកន បញ្ជាឱ្យ នាយកងទ័ពមុខ ឆ្លងទន្លេ ទៅចោមរោម វាយបន្ទាយកំពង់សៀម។ ដឹងថា ស្តេចកន បើក យុទ្ធនាការ វាយលុកដូច្នេះ, ព្រះចន្ទរាជា ប្រញាប់ ចម្លង រេហ៍ពល ៥ម៉ឺននាក់ ដាក់នៅត្រើយខាងកើត ចុងខែត្រអាសន្នុក។ បន្ទាប់មក ព្រះអង្គ លើកទ័ពហ្លួង ទៅបោះទ័ពនៅភូមិព្រៃករកាកោងនិង ឱ្យកងទ័ព ចំនួន រេហ៍ពល ១ម៉ឺននាក់ មាន ឧកញ៉ាយមរាជ ជា មេធំ លើកទៅព័ទ្ធ ពីព្រៃចំការលើចុះមក។ ចំណែកសម្តេចចៅពញាយោធាវិន្ទ ឃុំពល ១ម៉ឺននាក់ លើកតាមផ្លូវក្រោម គឺតាម មាត់ព្រៃខាងលិច កំណត់ឱ្យទៅជួបជុំ នៅបន្ទាយកំពង់សៀម។ តែ ក្បួនកងទ័ព ធ្វើដំណើរ យឺតយូរពេកព្រោះ តាមផ្លូវនោះមានទឹកលិចច្រើនណាស់។ ខនដំណើរនេះនាំឱ្យកងទ័ព ស្តេចកន វាយ បន្ទាយកំពង់សៀមបែក។ ព្រះចន្ទរាជា ទទួលយកបរាជ័យនេះ ទុកជាកំហុស របស់ព្រះអង្គ តែម្នាក់ឯង។ បន្ទាប់មក ព្រះចន្ទរាជា ទ្រង់ ត្រាស់បញ្ជា ឱ្យ នាយទ័ព លើកទ័ព ទៅវាយ បន្ទាយកំពង់សៀម យកពីសត្រូវមកវិញ។ ឃើញទ័ព ស្តេចត្រើយខាងលិច លើកមកជិតខ្សែការពារបន្ទាយ, នាយទ័ព ខាងស្តេចកនក៏លើកចេញមកទទួលច្បាំង។ ឧកញ៉ាវង្សាអគ្គរាជ មេទ័ព ខាងលិច តតាំងនឹងសត្រូវ តែធ្វើដកថយ បន្តិចម្តងៗ ដែលនាំឱ្យគូសត្រូវ រុលទៅមុខ តាមខ្លាំង

# សង្គ្រាម គ្នាឯង

ដោយមិនដឹងខ្លួន រហូតមកដល់ ភូមិសៀមបោយ។ នៅទីនោះ ស្រាប់តែមាន ពេលរហ៏ ខាងលិច រត់ចេញពីព្រៃ វាយពីខាង ក្រោយទ័ព របស់ខ្លួន នាំឱ្យតស៊ូពុំបាន ក៏ដកទ័ពរត់មកដល់ ព្រៃមួយ តែ នៅទីនោះដែរ ក៏ជួបប្រទះនឹង ទ័ពហ្លួង ពេញ ត្រកូល លើកមកវាយបន្ថែមទៀត។ ពេលរហ៏ ខាងស្តេចកន ក្រឡេកឃើញ ព្រះចន្ទរាជា គង់លើហត្ថី (ដំរី) ហាក់បីដូច ជា មាន រាជបារមី ដែលធ្លាប់បានឮគេនិយាយ ក៏រត់ចូលទៅ ថ្វាយបង្គំសុំព្រះរាជទាន អភ័យទោស។ ព្រះអង្គក៏លើកទោសឱ្យ ទាំងអស់, រីឯ នាយទ័ព ២នាក់ ខាងសត្រូវ នាំគ្នារត់ចូលព្រៃ អា កខ្លួនឯងស្លាប់ទៅ។ បន្ទាប់មក កងទ័ព ស្តេចខាងលិច ក៏ លើកទៅ ចោមវាយ បន្ទាយកំពង់សៀម។ នាយទ័ព ការពារ បន្ទាយ ទ្រាំតតាំង ពុំបាន ក៏នាំពេលរហ៏ រត់ចេញពីបន្ទាយ ចុះ ទូក តែដោយសារ ចំនួន អ្នកជិះច្រើនពេក នាំឱ្យទូកភ្លូក ជា ច្រើន, ខ្លះមិនចេះហែលទឹក ក៏លង់ទឹកស្លាប់, ស្លាប់ទាំង ចៅពញាមហាសេនា នាយទ័ពធំ ខាងកើត។ ស្តេចកន ដឹងថា បន្ទាយកំពង់សៀម ត្រូវបានសត្រូវ វាយយកវិញបាន ក៏បញ្ជូន កងទ័ពជើងទឹក ទៅជួយ ជើងគោក វាយយកបន្ទាយវិញ។ ដឹង ដូច្នេះ ព្រះចន្ទរាជា ត្រាស់បង្គាប់ឱ្យ ទ័ពជើងទឹក ដែល បោះទ័ព នៅ រកាកោង លើក ជាប្រញាប់ ទៅជួយទ័ពព្រះអង្គដែរ។ ចែវ ទូក មកដល់កំពង់ចាម ឃើញ ទូកចម្បាំង ប្រមាណ ១៥០ ទូក របស់ទ័ពខាងកើត ចត តាមច្រាំង ហើយ ទូក និមួយៗ មាន សេនា ៥ ឬ ៦ នាក់ នៅរក្សា, ឧកញ៉ាវិបុលរាជា នាយសេនាទ័ព

# សង្គ្រាម គ្នាឯង

ក៏ប្រញាប់ឱ្យរេហ៍ពល ចោម បាញ់ ចាក់កាប់ សត្រូវទាំងនោះ ឥតសំចៃដៃឡើយ ចាប់យក ទូកចម្បាំងខ្លាំង បានទាំងអស់។ នាយទ័ព និង នាយពល ជើងទឹក របស់ ស្ដេចកន ដឹង ដំណឹង អកុសលនេះ ក៏ស្លុតចិត្តអស់គំនិត ដែល នាំឱ្យ រេហ៍ពល មើល ឃើញ ការភិតភ័យ របស់ មេខ្លួន ក៏នាំគ្នារត់ខ្ចាត់ខ្ចាយ បែក ទ័ពទៅ។ ស្ដេចកន នោះបីជួបនឹងបរាជ័យ ក៏នៅតែចចេស បញ្ជូនទ័ព ទៅវាយយក បន្ទាយកំពង់សៀមទៀត។ ទ័ពទាំង សងខាង ច្បាំគ្នា ជា ច្រើនគ្រែ ច្រើនគ្រា ម្ដងចាញ់ ម្ដងឈ្នះ ពុំ បានសម្រេចជ័យជំនះ ទៅខាងណាៗឡើយ។ លុះដល់ រដូវ រាស្ត្រ ធ្វើស្រែ ស្ដេចកន ក៏ផ្អាក ការវាយប្រហារ។ យល់ឃើញថា សង្គ្រាម នាំតែទុក្ខ ដល់ អាណាប្រជារាស្ត្រ ស្ដេចកន មានគំនិត ស្នើ ចែក ផែនដី ជា ពីរស្មើគ្នា ហើយ ប្រើ ទូត ឱ្យនាំសារ ថ្វាយ ព្រះចន្ទរាជា ជូន ជា ដំណឹង។ តែ ស្ដេច ពេញត្រកូល បដិសេធ សំណើរនេះ ដោយ ត្រាស់ថា ៖ ‹‹ក្រុងកម្ពុជា រាជធានី ជា ព្រះរាជសម្បត្តិ អំពី បរមរាជអយ្យកោអយ្យិកាយើង រៀងមក។ ឯ ព្រះស្ដេចកន អ ម្ចាស់ឯងនោះ ប្រៀបដូចជាចោរ មកលួចផែនដីយើង ហើយ មកសូមចែកសម្បត្តិម្ចាស់ទ្រព្យនេះ តើឯងឃើញថា គប្បីហើយ ឬ ? ប៉ុន្តែឥឡូវនេះ បើម្ចាស់ឯង ចង់ឈប់សង្គ្រាម ក៏ឈប់តាម ចិត្តចុះ។ តែថា ម្ចាស់ឯង ថយទៅជាមុនចុះ សូមអញថយទៅ ជាក្រោយ››។ លុះទូត នាំដំណឹងអវិជ្ជមាន មកប្រាប់ស្ដេចកន, កន ក៏និយាយថា ៖ ‹‹ចៅពញាចន្ទរាជា ដែលមកលួចវាយស្រុក ខាងលិចនេះ តើអាចទុកជា ចោរ ដែរឬ ពុំមែនជាចោរទេ ?››។

## សង្គ្រាម គ្នាឯង

ដូច្នោះ ស្តេចកន ក៏ដកទ័ពថយ ហើយ វិលត្រឡប់ ទៅក្រុងពិជ័យនគរវិញ, រីឯ ព្រះចន្ទរាជា ដកទ័ពថយ, ទ្រង់ យាង ត្រឡប់រហូតទៅ ខែត្រ ពោធិសាត់ ហើយ ទ្រង់ គង់នៅទីនោះ ជាបន្ទាយទ័ពលួង។

កិច្ចព្រមព្រៀង ជាគណ្ឋី[32] នៃ សន្តិភាព[33] រវាង ព្រះចន្ទរាជា នឹង ស្តេចកន មានមកដល់ឆ្នាំ ១៥២១។ តាំង ពី ផ្តើម សង្គ្រាម នៅឆ្នាំ ១៥១៥, ស្តេចទាំងសងខាង តែង ស្វែងរក ល្បិច គ្រប់បែបយ៉ាង ដើម្បី យកឈ្នះ គូសត្រូវ។ ឧកញ៉ាចក្រី កែវ ខាង ព្រះចន្ទរាជា នឹងគិតថា នៅពេល សន្តិភាពនេះ ស្តេចកន ច្បាស់ជាប្រហែសខ្លួន ដូច្នេះ គួរ ប្រើ សេនាមានថ្វីដៃ ខាងបាញ់កាំភ្លើងទៅ លួចបាញ់សម្លាប់ រាជ្យភង្គ នេះ ប្រហែល ជា បានសំរេច ដូចក្តីប្រាថ្នា។ គិចរួច ក៏ប្រើ សេនា ៤នាក់ ទៅក្រុងពិជ័យនាគ។ តែ គំរោងធ្វើឃាត មិនបានសម្រេច ដូចបានរៀបចំនោះឡើយ។ ព្រះចន្ទរាជា ស្តេច ដឹងគំរោងនោះ ទ្រង់ មាន កំហឹងនឹង ឧកញ៉ាចក្រី កែវ ព្រោះ គំនិតនេះ វា ខុសច្បាប់ ខុសទំនៀមទ័ពក្រស័ត្រ គឺ ធ្វើដូច អាកន ជា មនុស្សព្រៃ ប្រើ មនុស្ស មកឱ្យ ធ្វើឃាតអញ។ តែ ព្រះអង្គ អភ័យទោសឱ្យ ចក្រី កែវ តែ ព្រះអង្គ

---

32 គណ្ឋី :ដោយកាត់យល់, ដែលស្ងៀម។

33 កិច្ចព្រមព្រៀង នៃ សន្តិភាព នោះ ផែនដី ខាងលិច នឹង ខាងកើត មាន ទំនាក់ទំនង ពាណិជ្ជកម្ម គ្រប់ទំនិញ លើកលែង តែ អាវុធ។

## សង្គ្រាម ក្លាងខ

ក្រាស់ប្រដៅថា វិស័យសឹកក្រស័ត្រ បើថានឹងគិត ជា ឧបាយកល បែបណាៗនោះ លុះត្រា តែកំពុងប្រទល់ទ័ពគ្នា។

ស្តេចកន ទទួលបានព័ត៌មានថា ព្រះចន្ទរាជា ទិញ កាំភ្លើងតូចធំ សំរាប់ទុកច្បាំង ក៏ប្រើឈ្មួញអារុជ ទៅទិញកាំភ្លើងធំ ១៥០ ដើម និង កាំភ្លើងតូច ៣០០ ដើម នៅ ប្រទេសម៉ាឡាយូ។ សំពៅ ពីរ ផ្ទុក អារុជ នោះ ដឹកមកស្រុកខ្មែរ ត្រូវខ្យល់ផាត់សំពៅមួយ ទៅជាប់នៅពាម (ប្រហែលជាពាមមាត់ជ្រូក) សំពៅមួយទៀត ទៅជាប់នៅស្រុកកំពត។ នោះនាយកងទ័ព ខាងលិច ចាប់បានសំពៅទាំងពីរ ឃើញមាន អារុជ ទាំងនោះ ក៏ប្រមូលដាក់រទេះ ឱ្យមេឃុំ នាំទៅថ្វាយ ព្រះចន្ទរាជា នៅស្រុកបរិបូណ៌។ ព្រះស្តេចខាងលិច ទទួលយក អារុជសឹក របស់សត្រូវដោយ ព្រះអំណរក្រៃ។

និយាយអំពី ស្តេចកន ម្តង, នរនេះ ក៏សម្រេចចិត្ត ផ្តាច់កិច្ចសន្យា នៃ សន្តិភាព ហើយ កេណ្ឌទ័ព ជាថ្មី មាន ចំនួន រេហ៍ពល ១ សែន ៤ ម៉ឺន នាក់ លើកទៅច្បាំងនឹង គូសត្រូវ នៅខែត្របរិបូណ៌។ ព្រះចន្ទរាជា លុះទ្រង់ ជ្រាបគ្រប់ប្រការហើយ ក៏ចាប់រៀបចំយុទ្ធសាស្ត្រ ទទួលច្បាំងនឹងសត្រូវ។ ព្រះអង្គ ឱ្យនាំទ័ពដំរី ៣ ពាន់ក្បាល ទៅបង្កប់ក្នុងព្រៃ តាមផ្លូវ ដែល ទ័ពសត្រូវ នឹងដើរមក និង ទ័ពសេះ ៥ រយក្បាល ជា កងជន្ល និង ទ័ពមុខឆ្វេង ស្តាំ ក្រោយ រៀបចំ ជា ក្រឡាសឹក ព្រមទាំង កងទ័ពជើងទឹក មាន ទូកចម្បាំង ៤ រយ ទូក ហែរព្រះអង្គ ជា ទ័ពហ្លួង ។ ព្រះ

# សង្គ្រាម ត្លាងខ

អង្គ ទ្រង់គ្រឿង កកុធភ័ណ្ឌ សម្រាប់រាជយុទ្ធ ឡើងគង់ ព្រះទីនាំពិជ័យរាជកញ្ជរ លើកអស់និករ ចេញទៅ សមរភូមិ។ កងទ័ពមុខ ស្ដេច ខាងលិច លើកទៅដល់ ស្ទឹងក្រាំងពន្លៃ ក៏ជួបប្រទះនឹងសត្រូវ ហើយ ក៏ចូលតាំងច្បាំងនៅទីនោះយូរបន្តិច នាយទ័ព ក៏នាំពលរត់ថយក្រោយ មកដល់ខាងលិច ភូមិឈូកសខែត្រលង្វែក, ខណៈនោះ មាន ពលសេះ ៤០ នាក់ ចេញមកកាល់[34]ពលខ្លួន ឱ្យរៀបចំជាជួរទ័ព ដើម្បី ចូលប្រយុទ្ធ តតាំងនឹងសត្រូវ ជាថ្មីម្ដងទៀត តែ ក្រោយបន្តិចមក ក៏បណ្ដែតទូកថយ ចេញពី សៃរៀនប្រយុទ្ធ ដែលនាំឱ្យ នាយកងទ័ពសត្រូវនឹកភ្នកថា កងទ័ព ខាងលិច កំពុង ដកខ្លួនរត់ ក៏បរពលសម្រុកលុក តាមដងស្ទឹងជ្រៃ កុំឱ្យសត្រូវរត់រួច។ តែ ជួបប្រទះនឹងកងពលខ្លាំងមួយកង ចេញមកវាយប្រហារ មួយស្របក់ ក៏ដកថយទៀត។ ឃើញដូច្នេះ នាយកងទ័ព ខាង ស្ដេចកន ក៏មានចិត្តជោរឡើង មិតតែដេញតាមទៅ ត្រាតែជួបនឹងកងទ័ពធំ របស់ព្រះចន្ទរាជា មាន ឧកញ៉ាក្រឡាហោម ជា នាយកកងទ័ព ដែល មកបង្កប់ទ័ព ចាំនៅ វាលស្រាបអង្គាមនោះ។ លើកនេះ កងទ័ព ស្ដេចខាងលិច ចេញមក ទាំងសងខាងផ្លូវទទួលច្បាំងយ៉ាងមាំមួន មាន ទាំង ទ័ពដំរី ៣ រយ ក្បាល លើកមកជល់ជាន់ រេហ៏ពល ខាង ស្ដេចកន។ នៅចំពោះមុខ នរនេះ ព្រះទីនាំងពិជ័យរាជកុញ្ជរ របស់ ព្រះចន្ទរាជា ដែលចេះកាន់ នូវ

---

34 កាល់ : កិ. ខារខាំងមិនឱ្យប្រចឡកប្រចឡំគ្នា។

# សង្គ្រាម គ្នាឯង

អាវុធ គ្រវែងចាក់ សម្លាប់ពួកពលស្តេចកន បណ្តាឱ្យស្លាប់ជាច្រើន។ ស្តេចកន ទ្រាំពុំបាន ក៏បែកទ័ព រត់ កាត់ព្រៃ មកដល់ព្រៃករលាស្អៀរខាងស្តាំ។ នៅទីនោះ ស្តេចកន ជួបប្រទះនឹងកងពលសត្រូវម្តងទៀត ហើយកងនោះ ចូលវាយប្រហារឥតត្រាប្រណី ដេញទ័ពស្តេចកន ខ្ចាត់ខ្ចាយទៅទៀត។ នៅសល់តែកងអង្គរក្ស ១០០ នាក់ វាយរំដោះ ស្តេចកន ជា អម្ចាស់ខ្លួន ចេញពីការហ៊ុមព័ទ្ធសត្រូវបាន។ តែនាំរត់មកដល់ ភូមិតាជេស ខែត្រលង្វែក ត្រូវចាំបាច់ ឆ្លងទន្លេ តែមានតែ ២០នាក់ប៉ុណ្ណោះ ចេះហែលទឹក, ដូច្នេះ អ្នកទាំងនោះ ហែលតោងសេះ ស្តេចកន ទៅកោះតូច រួចឆ្លងទៅទៅស្ទឹងស្ទួតជើងព្រៃ ជាត្រើយខាងកើតសំដៅទៅតំបន់ដូនម៉ៅ ហើយនាំគ្នាឡើងច្រាំងទៅ តែ សេះស្តេចកន ហត់នឿយកម្លាំងពេក ក៏លិចទឹកស្លាប់ទៅ។ បាត់ដំណឹងពីក្តួយ៣ថ្ងៃ ក៏មានការបារម្ភក្រៃ ចៅហ្វា កៅ ក៏នាំ ពល ១ ពាន់នាក់ និង ខ្ទាន់ផ្លូប្លួយកង ទៅ ដូនម៉ៅ ក៏ជួបក្តួយ ដូចបានគិតទុក កំពុងរត់ឡើងច្រាំង តែ មានទូកសត្រូវ ចែវយ៉ាងលឿន មករកក្តួយ ហើយ ក៏បញ្ជាឱ្យខ្ទាន់ផ្លូ បាញ់ ផ្លូ និងកាំភ្លើង ទៅលើទូកសត្រូវ កុំឱ្យ រេហ៍ពលនោះ ឡើងតាមបាន។ ស្តេចកន រត់រួចខ្លួន សម្រាកមួយយប់នៅទីនោះ។ ព្រឹកឡើង ចៅហ្វា កៅ អញ្ជើញ ក្តួយ វិលត្រឡប់មក ក្រុងស្រឡប់ពិជ័យព្រៃនគរ វិញ។ ដំរី ដែល ជា ជំនិះ របស់ ស្តេចកន ឈឺស្រុតស្លាប់នៅពេលដែលកំពុងធ្វើដំណើរ។

## សង្គ្រាម ត្នាឯង

បរាជ័យលើកនេះ ជា អំពើ របស់ខ្លួនផ្ទាល់ ព្រោះ ស្តេចកន ខ្លួនឯង ជា អ្នកដឹកនាំកងទ័ព ហើយ ភ្លាត់គំនិត នាំឱ្យចាញ់ឧបាយកលសត្រូវ ដូច មេទ័ពខ្លួន ដទៃទៀតដែរ។ ដូច្នេះ កន ក៏ចាប់មាន ការសង្ស័យនឹងបុណ្យបារមី របស់ខ្លួន ក៏លួច យំសោក ជារុំរ៉ៃ ក្រៃពេកណាស់។ ឃើញក្អួយ មានទឹកមុខស្រពោន ចៅហ្វា កៅ និយាយថាៈ យើង យក ស្រុកស្រីសឈរ ជា មូលដ្ឋានសឹកមុខ សំរាប់ តតាំងនឹងសត្រូវ ដូច្នេះ យើង ទៅរៀបចំ កងទ័ព ជាថ្មីនៅទីនោះ មុននឹង វិលត្រឡប់ទៅ រាជធានី វិញ។ បន្ទាប់មក ចៅហ្វា កៅ ក៏វិលត្រឡប់ ទៅ ការពារបន្ទាយ ក្រុងស្រឡប់ពិជ័យព្រៃនគរ វិញ និង កេណ្ឌទ័ព បន្ថែម, រី ស្តេចកន វិញ នៅរង់ចាំ នៅ បន្ទាយ ស្រុកបាសាន។

នៅឆ្នាំ ១៥២៤ ព្រះចន្ទរាជា បន្ទាប់ ពីទទួលបាន ជ័យជំនះច្បាស់លាស់ លើ កងទ័ព ខាងកើត, ព្រះអង្គ ក៏រៀបចំយុទ្ធសាស្ត្រផ្តាច់ គមនាគមន៍ រវាង ក្រុងស្រឡប់ពិជ័យព្រៃនគរ នឹង ស្រុកស្រីសឈរ ដោយ ដាក់ ទ័ព នៅ មាត់ឃ្លុង និង ភ្នំពានជាំង និង បញ្ជូន កងទ័ព ទៅឈរនៅខែត្រព្រៃវែង។ កងទ័ពទី១ សំរាប់ ស្ទាក់ផ្លូវ កុំឱ្យ សម្តេចចៅពញា ហែង[35] ជា ឱពុកក្មេងស្តេចកន លើកមកជួយ កូនប្រសាបាន។ កងទ័ពទី២ សំរាប់ ស្កាក់ផ្លូវ ចៅហ្វា កៅ កុំឱ្យមកសួរគ្នាបាន។

[35] កូនស្រី របស់ ពញា ហែង ឈ្មោះ ព្រះនាង ផាលែន ជាស្នំឯក។

# សង្គ្រាម ត្បាងឯ

បានដំណឹងថា កងទ័ព ព្រះចន្ទរាជា លើក មកដល់ ខែត្រព្រៃវែង, ក៏សម្រេចចិត្ត លើកទ័ព ចោលបន្ទាយបាសាន ព្រោះ កងទ័ព ការពារបន្ទាយ មាន ចំនួន តិចពេក បើប្រៀបនឹងទ័ពសត្រូវ ខាងលិច។ កំពុងធ្វើដំណើរ ស្តេចកន ស្រាប់តែជួបប្រទះនឹងកងទ័ព ចៅពញា សុខ ជា កូន តាមឿង។ រេហ៍ពល ទាំងសងខាង  ក៏បានចូលច្បាំងគ្នាពីព្រឹកលុះថ្ងៃត្រង់តែពុំទាន់ឈ្នះចាញ់។ ឱកញ៉ាចក្រី ទេព កូនទី៣ តាមឿង បានដំណឹងថា ស្តេចកន បោះបង់បន្ទាយ ហើយ កំពុង ជាប់ច្បាំងនឹងកងទ័ពប្អូន ក៏លើក កងពលខ្លួន ទៅជួយ។ ស្តេចកន រុលទៅមុខមិនរួច ក៏បែរកងទ័ព វិលត្រឡប់មកបន្ទាយបាសានវិញ។ តែក្តួយស្តេចកន ជា នាយពលសេះ ៥០០ ក្បាល ឃើញ មា រត់ចូលបន្ទាយវិញ ក៏ វាយជ្រែកចង់ចូលដែរ តែ ចូលពុំបាន ក៏នាំទ័ពបរប្រញាប់ ទៅជម្រាប ចៅហ្វា កៅ នៅបន្ទាយពិជ័យព្រៃនគរ។ បានដំណឹង អកុសលនេះភ្លាម ចៅហ្វា កៅ ក៏លើកទ័ព ៥ម៉ឺននាក់ ទៅជួយក្តួយ។ មកដល់ សមរភូមិ ក៏បញ្ជា រេហ៍ពល ឱ្យវាយជ្រែកចូលបន្ទាយបាសាន អស់រយៈពេល ៣ ថ្ងៃ តែ ចូលនិង ចេញ ពុំរួច។ ព្រះចន្ទរាជា បានដំណឹង ក៏បញ្ជូនកងទ័ពបន្ថែម ហើយ ព្រះអង្គ លើកទ័ពហ្លួង ទៅបោះទ័ពនៅទន្លេបិត។ ទ្រង់ ត្រាស់បង្គាប់ឱ្យ ឧកញ៉ាមហាមន្ត្រី យុំពល ១ម៉ឺននាក់ ទៅបង្កប់ក្នុងព្រៃ រំលោង ប្រប ផ្លូវចង្អៀត រង់ចាំចាប់ ស្តេចកន។

# សង្គ្រាម ត្រាងខ

បន្ទាប់មក ថៅហ្វា កៅ វាយបើកផ្លូវ ឱ្យ ស្ដេចកន រត់ចេញពីបន្ទាយបាន ក៏នាំគ្នា ពល ស្រូតរូត ឆ្លងទន្លេតូច ទៅតាមផ្លូវមេសព្រះចន្ទ កាត់តម្រង់ទៅក្រុង ពីជ័យព្រៃនគរ។ តាមផ្លូវនោះឯង ដែល ព្រះចន្ទរាជា ទាយទុកមុន ហើយរៀចចំ ដាក់ទ័ពពួនស្ទាក់។ ដឹងថា ចូល អន្ទាក់ខ្លាំងហើយ ថៅហ្វា កៅ ស្រែកប្រាប់ក្អួយថា ៖ ‹‹ព្រះភាគិនេយ្យោ[36] គិតតែបុកទៅមុខទៅ កុំគិតមាអ៊ី !››។ ស្រែកផ្ដាំរួចស្រេច ថៅហ្វា កៅ ក៏បែរទ័ពមកប្រកាប់ប្រចាក់នឹងទ័ព ថៅពញា បែន មេទ័ព ខាងលិចដែលកំពុងដេញខ្លួនពីក្រោយ។ ខណៈនោះ សេះ ពញា បែន ស្រុតជើង ក្នុងអន្លុង បើកឱកាសឱ្យ ថៅហ្វា កៅ ពួយនឹងលំពែងត្រូវម្ចាស់ ធ្លាក់ពីសេះស្លាប់មួយរំពេច។ បន្ទាប់មក ក៏បរសេះ ស្រូតទៅតាមក្អួយ។ មកដល់ផ្លូវរំលោង មា នឹង ក្អួយ ក៏នាំគ្នាស្រូតទៅរកកន្លែងសុខ។ តែជា អកុសល ក៏ជួបប្រទះ ជាថ្មីកងពលសត្រូវ មកស្កាត់ពីមុខ។ ទើសនឹងប្រាំងខ្ពស់ ក៏ពុំអាចដាកឆ្វេងស្ដាំ នឹងថយ ក៏ពុំរួច, ស្ដេចកន ភ័យណាស់ ក៏ក្រាបលើខ្នងសេះយំ។ កៅ យល់ដូច្នោះហើយ ក៏ចាប់ដៃទាញឡើង ហើយថា ៖ ‹‹បើមា ស្លាប់ សុំ ក្អួយ ស្លាប់តាម, បើ មា មាន ជីវិតរស់ទេ ក្អួយនឹងភ័យខ្លាចវាថ្វី››។ ថាហើយ ថៅហ្វា កៅ ក៏ស្រែកទៅ រេហ៍ពលខ្លួន ថា ៖ ‹‹បើយើងមិនខំប្រឹង គង់តែស្លាប់នឹងគ្រាប់កាំភ្លើងគេ អស់មិនខាន។ យើង ត្រូវស៊ូ ចូលទៅប្រកាប់ បើ

---

36 ភាគិនេយ្យោ : ក្អួយប្រុស។

## សង្គ្រាម ត្រាងខ

ស្លាប់នឹងប្រយុទ្ធ យើងក៏មានកេរ៍ឈ្មោះដែរ បើរស់ យើង ក៏បានរួចទៅបន្ទាយ ជួបប្រពន្ធកូនជាមិនខាន››។ ឮសម្ដី មេទ័ពខ្លួនកាលណា រេហ៏ពល ក៏ចូលចិត្ត ពួតដៃគ្នា ចូលវាយទម្លាយទ័ពមុខសត្រូវ ត្រាតែរួចចេញមក សល់នៅតែមនុស្ស ៥ ពាន់នាក់។ ទ័ពសល់នោះ ក៏ខំស្រូតរូត រត់ទៅដល់ ច្រកចង្អៀតផ្លូវភ្នំពានជាំង, អស់កម្លាំងពេក ក៏នាំគ្នាឈប់ដាំបាយស៊ី។ តែត្រូវ សត្រូវ ប្រមៀលថ្ម បាញ់នឹង កាំភ្លើង ធ្នូ ស្នា ស្លាប់ជាច្រើនទៀត។ ស្ដេចកន និង ថៅហ្វា កៅ ក៏បន្តរត់ទៅទៀត, តែទ័ពមហាទេព ខាងលិច មិនហ៊ានដេញតាម ព្រោះខ្លាចចាញ់ឧបាយកលសត្រូវ ព្រោះ គេរត់ចូលជ្រៅណាស់ទៅហើយ មកដល់ក្នុងទឹកដី របស់គេ។ ដឹងថា ស្ដេចកន រត់រួច, ព្រះចន្ទរាជាត្រាស់បញ្ជាឱ្យលើកទ័ពធំ ទៅវាយបន្ទាយពិជ័យនគរ។ លើកមកដល់បន្ទាយខ្លាំង ក៏ចូលវាយប្រហារ គ្មានបង្អែបង្អង់ឡើយ។ តែកងទ័ព ការពារបន្ទាយ វាយតប ដោយពួយនឹងលំពែង និងបាញ់នឹងកាំភ្លើង បណ្ដាលឱ្យស្លុតស្លាប់រេហ៏ពល ខាងលិច អស់ជាច្រើន។ កងទ័ព ទាំងសងខាង បន្តច្បាំងគ្នា រហូតដល់រដូវ វាស្រ្តផ្ទើស្រែ ក៏ សម្រេចរួម ផ្អាកសង្គ្រាម មួយរយៈ។ នៅក្នុងរយៈពេល ផ្អាក សង្គ្រាមនោះ ឧកញ៉ាយមរាជ សួស នាយទ័ព ខាងលិច ឱ្យកងកាំងភ្លើងមួយកង ទៅលួចបាញ់ ស្ដេចកន តែមិនបានសម្រេច។ ដឹង នូវអំពើខុសនឹងព្រះរាជបម្រាម, ព្រះចន្ទរាជា ត្រាស់បញ្ជាឱ្យ យក សួស ទៅប្រហារជីវិត ជា គម្រោ។

# សង្គ្រាម ត្នាងឯង

ចប់រដូវធ្វើស្រែកាលណា ស្ដេចកន ក៏កេណ្ឌកងទ័ព ជាថ្មី បាន ចំនួន ១៥.០០០ នាក់ ដើម្បី វាយប្រហារ បន្ទាយក្តុល ជាបន្ទាយ មុខ របស់ ស្ដេចខាងលិច មាន រេហ៍ពល តែ ៤.០០០ នាក់។ ចៅពញា សុខ កូន តាមឿង យកសេចក្ដីក្រាបទូល សម្ដេចព្រះ ភាគិនេយ្យោយសរាជា ជា កែវនាយកទ័ព ខាងលិច ប្រចាំការ សឹកនៅខាងកើត ថា៖ ‹‹ពលយើង ព្រះស្ដេចគ្រងរាជ្យ ទ្រង់ បន្ទុយ អស់ទៅហើយ បើយើងនឹង ឱ្យទៅកេណ្ឌទ័ព ថែមមក ទៀត ក្រែងពុំទាន់។ តែកាលបិតាទូលបង្គំ លោតអន្លង់សម្លាប់ ខ្លួន ទៅកេណ្ឌបិសាច ឱ្យជួយធ្វើការនោះ បានផ្ដាំទុកនឹងពញា ចាន់ មេស្នឹង ជា ភឿន ថា អាចនឹងធ្វើពិធី ឧទ្ទិស ដល់ សពឱ ពុកទូលបង្គំ សុំលោក ឱ្យជួយ ធ្វើការនេះ បើព្រះរាជា ត្រូវការ››។ សម្ដេចព្រះយសរាជា ទ្រង់ យល់ព្រម តាមសំណើរនេះ ហើយ ត្រាស់បញ្ជាឱ្យរៀបចំពិធី ជា បន្ទាន់។ ក្នុងគ្រានោះ បិសាច ពញាមឿង ចូលសណ្ឋិតនឹង មេស្នឹងចាន់ ហើយ ថ្លែងប្រាប់ គន័យ[37] ថា៖ ‹‹ឱ្យយកចំបើង ចង ជា រូបមនុស្ស ឱ្យច្រើនកាន់ ប្រឆេះ ឱ្យពួកពលចេះតែហ៊ោ បាញ់កាំភ្លើងពីចម្ងាយទៅ សុំ យើង កេណ្ឌទ័ពបិសាច ទៅជួយឱ្យសម្រេច››។ កូន តាមឿង ក៏ ធ្វើតាមបង្គាប់សម្ដីបិសាច ជា ឱពុក។ លុះដល់វេលាយប់ហើយ ក៏ឱ្យរេហ៍ពល យកចំបើង ចង ជារូបមនុស្សហើយ ចងប្រឆេះ នៅរូបចំបើងនោះ យកទៅដាក់ នៅក្បាលត្រោកជុំវិញ បន្ទាយ

[37] គន័យ : កូនប្រុស (ពាក្យនេះ សំរាប់ប្រើក្នុងកាព្យ)។

# សង្គ្រាម ត្នាងខ

ស្តេចកន។ ឯ បិសាចតាមឿង ក៏កេណ្ឌបិសាច ឱ្យតាំងហ៊ោ បីដូចជា គេមកប្លន់យកបន្ទាយ។ ទ័ព ស្តេចកន ឮហើយ ក៏តាំងតែបាញ់កាំភ្លើង ធ្នូ ស្នា ចោលដុំសិលា ពីបន្ទាយ ជាច្រើនរាត្រី។ កងទ័ពបន្ទាយ បាច់ អស់ព្រួញ ធ្នូ ស្នា រលោះទាំងគ្រាប់រំសេវ។ លុះដល់យប់គម្រប់ ១៥ថ្ងៃ នោះ ស្រាប់តែឮតាំងហ៊ោ វាយគងទូងស្គរ ក្រោមដី លើអាកាស ដូចរន្ទះ កក្រើកទាំងព្រះធរណីផង់ធូលី ក៏បក់បោក ចូលភ្នែក។ អស់សេនាទាហាន ខាងកើតទ្រាំពុំបាន ក៏បើកទ្វារបន្ទាយ រត់ទៅទិសអគ្នេយ៍ ប៉ងនឹងទៅខែត្ររោងដំរី ដើម្បីនឹងទៅពឹង ប្រទេសចាមឱ្យមកជួយ។ ឯស្តេចកន, សម្តេច កៅ, ស្នងភឹមព្រះនគរ នាំ អ្នកម្នាង ផាលែន រត់ចេញតាម ទ្វារប៉ម ទិសឦសាន ដើម្បី ទៅទិសខាងជើងកាត់ស្រុកលាវ តែ ត្រូវ ទ័ពបិសាច តាមទៅសំដែងឫទ្ធិ តាំងហ៊ោស័ព្ទស្គរដូចជាផ្គរ រន្ទះ ទាំងផែនប្រឹថពី គ្រប់ទីកន្លែង ដែលឈប់សម្រាក។ ដូច្នេះ ចេះតែ បន្តរត់ រហូត បែកផ្លូវគ្នា។ ស្តេចកន, សម្តេច កៅ និង ពញា ហែង រត់បែកទៅចុងខ្មាង ឯ អ្នកម្នាង ផាលែន និង ចក្រី នី រត់បែកផ្លូវ ទៅទិសខាងត្បូង ទៅដល់ភូមិគោកស្រុក។ ក្រោយមក កងទ័ពប្រដេញ ខាងលិចដេញទាន់ កងពល ចៅហ្វា កៅ និង នី ក៏ចូលកាប់ចាក់សម្លាប់ កៅ និង នី បាន។ ស្តេចកន, ពញា ហែង និង នាយទ័ពមួយចំនួនទៀត និង រេហ៍ពល ចំនួន ៥០០ ឬ ៦០០ នាក់ ក៏បន្តរត់ និង ពួន កុំឱ្យទ័ពប្រដេញ ខាងលិចរកឃើញ។ តែពេលមួយ ស្តេចកន កោះប្រជុំនឹងនាយទ័ពថា ៖ ‹‹យើងរត់មកឆ្ងាយណាស់

# សង្គ្រាម គ្នាឯង

ស្បៀងអាហារក៏តិចណាស់ កេណ្ឌពល ថែមទៀត ក៏ពុំបាន។ យើងយល់ថា ព្រះចន្ទរាជា ទ្រង់វិលត្រឡប់ទៅខេត្តពោធិសាត់ទៅហើយ នៅតែពញាយសរាជា ជាក្មួយអញបង្កើត ដូច្នេះ បើទុកជាម្ដេចម្ដា ក៏ចៅពញាយសរាជា មិនយកទោសអញទេ គង់ឱ្យអញ ធ្វើជា សម្ដេចចៅហ្វាដែរហើយ ពួកឯងរាល់គ្នា ក៏គង់តែបានសេចក្ដីសុខដែរ។ អញ យល់ឃើញថា យើងចាក់ចោលគ្រាប់រំសេវឱ្យអស់ ហើយ ទៅសុំចុះចូលវិញ ឃើញថា បានសេចក្ដីសុខប្រសើរ››។

នៅឆ្នាំ ១៥២៥ ស្ដេចកន ក៏នាំរេហ៍ពល មកដល់វត្តគរ, នៅទីនោះ មេគយ អរជូន កៃ ដឹងដំណឹងនេះហើយ ក៏កេណ្ឌពលចោមចាប់បាន នាង ផាលែន និង ស្ដេចកន។ ស្ដេចកនស្រែករោទ៍ ជា ខ្លាំង ហើយថា : ‹‹អញមិនគួរជាឱ្យគេចាប់បានសោះ››។

អរជូនកៃ គិតថា ‹‹បើបញ្ជូនខ្លួន ស្ដេចកន និង នាង ផាលែន ទាំងរស់ ទៅថ្វាយ សម្ដេចយសរាជា នោះត្រូវជាក្មួយ ស្ដេចកនផង កាលណានឹងហ៊ានសម្លាប់ ឱពុកមា របស់ខ្លួន។ ដូច្នេះ បើកន រួចខ្លួន ហើយ ឡើងជាធំ ច្បាស់ ជា វា សងសឹកនឹងអញ ជាពុំខាន››។ គិតឃើញដូច្នេះហើយ ក៏ឱ្យសេនា កាត់ក្បាល ស្ដេចកន និង នាង ផាលែន ដាក់ជាល យក ទៅថ្វាយ សម្ដេចព្រះភាគិនេយ្យោរាជា ព្រមទាំងឱ្យ ប្រហារជីវិត ទាំងអស់ស្ម័គ្របក្ស ពួកទាំង ២៥ នាក់ទៀត។

# សង្គ្រាម ត្រាងង

**សាច់រឿង** (scénario)

គំនិត របស់ ស្តេចកន មក សុំចុះចូលនឹង សម្តេចភាគិនេយ្យរាជា ជា ក្តួយបង្កើត គឺនៅក្នុង ល្បិច បញ្ចុះបញ្ចូល ក្តួយ ឱ្យរួមនឹងខ្លួន ដើម្បី ប្រឆាំងនឹង ព្រះចន្ទរាជា។ ហេតុផល នឹងអាចកៀងគរ ក្តួយបាន គឺ ពន្យល់ ក្តួយ ថា ក្តួយ ជា ទាយាទ ពេញសិទ្ធិ ដូច្នេះ ជា ស្តេច ត្រូវបន្តរាជ្យ ពី ព្រះស្រីសុគន្ធបទ ជា ព្រះរាជាបិតា។ ការឡើង គ្រងរាជសម្បត្តិ នៃ ព្រះចន្ទរាជា ទុក ជា ការបំពាន រាជប្រពៃណី ដូច្នេះ ព្រះចន្ទរាជា ជា រាជ្យភង្គ ដូចដែល ព្រះអង្គ ចោទប្រកាន់ មកលើរូបខ្លួនដែរ។ មួយវិញទៀត ការចុះចូល របស់ខ្លួន គឺ អាចទុក ជា ជ័យជំនះ របស់ សម្តេចភាគិនេយ្យរាជា ផ្ទាល់ មិនមែន ជា ជោគជ័យ របស់ ព្រះចន្ទរាជា នោះទេ ព្រោះខ្លួន ពុំបាន សុំចុះចូលនឹងព្រះអង្គនោះឡើយ។ ដូច្នេះ អាណាប្រជានុរាស្ត្រ ខាងកើត នឹងបន្ត គាំទ្រ ខ្លួន និង សម្ព័ន្ធមេត្រីនឹងក្តួយ ដើម្បី ប្រត្យាស្ថាបនា រាជវង្ស ព្រះស្រីសុគន្ធបទ ដែល មាន ក្តួយ ជា ព្រះទាយាទ។ ពិតណាស់ហើយ ថា គេ អាចចោទខ្លួន ជា អ្នកសម្លាប់ ព្រះស្រីសុគន្ធបទ ដើម្បី ដណ្តើម រាជសម្បត្តិ តែ ទំនាស់ របស់ខ្លួន នឹង ព្រះអង្គ ជា ការ ការពារខ្លួន ព្រោះ ព្រះអង្គ មាន គោលបំណង សម្លាប់ខ្លួន ដោយ គ្មាន ហេតុផលទាល់តែសោះ ហើយ មរណភាពព្រះអង្គទៀត គឺ នៅក្នុងសង្គ្រាម ដូច្នេះ វា គ្មាន លក្ខណៈ ជា ការក្បត់នោះទេ។ មួយវិញទៀត នៅពេល ដែល ព្រះស្រីសុគន្ធបទ សុគត

# សង្រ្គាម គ្នាឯង

ទៅ ត្រូវបាន បិតាលៀង សម្តេចភាគិនេយ្យរាជា នាំព្រះអង្គរត់ទៅស្រុកសៀម ដែលនាំឱ្យ ព្រះរាជាបល្ល័ង្ក នៅទំនេរ ដូច្នេះ ការឡើងគ្រងរាជសម្បត្តិ របស់ខ្លួន វា គ្រាន់ជា អំណោយផល នៃស្ថានការណ៏នេះ តែប៉ុណ្ណោះ។ ឥឡូវ សម្តេចភាគិនេយ្យរាជា ក្លាយ ជា ស្តេច ជិនបុត្រ ហើយ ថែមទាំងមាន សមត្ថភាព គ្រប់គ្រាន់ នឹង គ្រងរាជាសម្បត្តិ បាន។ ដូច្នេះ ការថ្វាយ រាជ្យ ត្រើយខាងកើត ដល់ព្រះអង្គ បន្ទោះអាសន្ន ទុកជាមូលដ្ឋានមាំមួនសំរាប់ ច្បាំងនឹងព្រះចន្ទរាជា ដើម្បី បង្រួបបង្រួម ស្រុកខ្មែរ ឱ្យទៅជាតែមួយ នៅក្រោមម្លប់ ស្វេតច្ឆត្រ តែមួយ ដែល មានព្រះមហាក្សត្រ ពេញវង្ស តែមួយ ជា ម្ចាស់ផែនដី គឺ ជា អំពើល្អសំរាប់ជាតិ និង ព្រះមហាក្សត្រ ដែលខ្លួនត្រូវធ្វើ សំរាប់ឱ្យអាណាប្រជានុរាស្ត្រ រដោះទុក្ខ។ សាច់រឿងនេះ វា អាចនឹងកើតឡើងបាន តែ ដោយសារ ពញា អរជូន កែ សម្រេចចិត្ត ដោយខ្លួនឯង កាត់ក ស្តេចកន ក្នុងគោលគំនិត ការពារខ្លួន តែប៉ុណ្ណោះ ព្រោះខ្លាច ស្តេចកន សងសឹកខ្លួន បើសិន ជា ក្លួយលើកទោសឱ្យ ឱពុកមា។ គេ អាចទុក ទង្វើឯកជននេះ ជា កម្មផល របស់ ស្តេចកន ឬ ក៏ ជា ការធ្វេសប្រហែស ដែល មិនបានរៀបចំផែនការ ឱ្យបានម៉ត់ចត់។ ដូច្នេះ មាន គំនិតល្អ តែ ខ្វះការរៀបចំល្អ វានឹងអាចក្លាយជា អាវុធ សម្លាប់ខ្លួនឯង។

# សង្គ្រាម ត្នាឯខ

## តើមូលហេតុអ្វី បាន ជា ស្ដេចកន ចាញ់ ព្រះចន្ទរាជា ?

ស្ដេចកន ច្បាំងឈ្នះ ព្រះស្រីសុគន្ធបទ ព្រោះ ជា មនុស្ស មាន ប្រាជ្ញា ហើយ មាន ជំនឿ ទៅលើ សភាវគតិ របស់ខ្លួន ដែលនាំ បង្កើត នូវ ធម្មារម្មណ៍[38] (intuition)។ តាម បញ្ញា គឺ ចាប់យកអ្វី ដែលជា គំនិតអរូបិយ មក ចងភ្ជាប់ នៅក្នុងចិត្ត ជា ទ្រឹស្ដី។ ទង្វើនេះ ជា ការចាំបាច់ តែ មិនទាន់គ្រប់គ្រាន់ទេ ព្រោះ នៅក្នុង សង្គ្រាម គ្រប់ វិស័យ ឬ នៅក្នុង អ័ព្ទ នៃ សង្គ្រាម អ្វី ក៏ មិនជាប្រាកដ, ពិបាកយល់, ផ្លាស់ប្ដូរ និង រត់បាត់ទៅ, ដូច្នេះ នៅក្នុង ស្ថានភាព បែបនេះ សភាវគតិ វា ផ្ដល់ នូវ ជំនួយ ដ៏មានតម្លៃណាស់ គឺ អនុញ្ញាតឱ្យ ‹‹សេចក្ដីឈ្លាសវៃ›› (flair), ‹‹ផ្លេករមិល[39]›› ចាប់យកបាន នូវអ្វី ដែលកំពុងកើតឡើង នៅក្នុងនាកាលដ៏ល្អមួយ។ ការណ៍នេះ ជួនកាល គេ ឱ្យឈ្មោះថា ជា ‹‹ការប៉ិនប្រសប់›› (coup de génie) ដែលនៅក្នុងនោះ វា មាន ធម្មារម្មណ៍។ ការប៉ិនប្រសប់ បែបនេះ ជា លាភជ័យ វា សមនឹងបាន ព្រោះ ‹‹ វា ជា ទម្រង់ រចិត[40] ដ៏ប្រសើរ នៃ សមត្ថកិច្ច››។

ជាការពិត ស្ដេចកន ច្បាំងនឹង ព្រះស្រីសុគន្ធបទ ឥត គគាត[41] ព្រោះ ខ្លួន មាន ជំនឿ ជាក់ច្បាស់ ថា ខ្លួន ជា មនុស្ស មាន ប្រាជ្ញា ជាង ដៃគូ ដូច្នេះ គ្រប់ ឧបាយកល ដែល ខ្លួន ប្រើ គឺ ធ្វើ

38 ធម្មារម្មណ៍ : ន. អារម្មណ៍របស់ចិត្ត។
39 ផ្លេករមិល : ក្រឡេកមើលមួយភ្លែត, coup d’œil។
40 រចិត : គុ. រៀបចំ។
41 គគាត : កិ. ឥតក្រែង។

ឡើង នៅក្នុង គំនិត ទុក ដៃគូ ជា មនុស្សល្ងង់។ ស្ដេចកន អាច ធ្វើបាន គឺ ដោយសារ ខ្លួន ស្គាល់ ចិត្តគំនិត របស់ សត្រូវ ច្បាស់លាស់ ព្រោះ ខ្លួន ធ្លាប់ជា បម្រើសផ្ទាល់ ដូចយ៉ាង ប្រើ ឧបាយកល បំបែក បង និង ប្អូន បានងាយស្រួល ព្រោះ ដឹង ថា អ្នកទាំងពីរ គ្មាន ការទុកចិត្ត នឹងគ្នា, ទាញយកប្រយោជន៍ ពីបងស្រី ព្រោះដឹងថា នាង មាន ឥទ្ធិពល ទៅលើស្វាមី ។ល។

ប៉ុន្តែ ស្ដេចកន ចំពោះមុខ ព្រះចន្ទរាជា វា ជា មនុស្សខុសគ្នា ព្រោះ ប្រាជ្ញាល័ព្ធ[42] របស់ខ្លួន កន មិនអាច អភិវឌ្ឍវា ឱ្យទៅជា អភិញ្ញាត[43] នៅចំពោះមុខ ស្ថានការណ៍ថ្មី។ ព្រះចន្ទរាជា វិលត្រឡប់ ពីស្រុកសៀម ដោយ មាន ជំនួយ អ្នកជំនាញយោធាសៀម ប្រើ យុទ្ធសាស្ត្រសឹកថ្មី ដែល សភាវគតិ របស់ កន ចាប់វាពុំបាន។ នៅចំពោះមុខ សត្រូវខ្សោយ ព្រោះមាន ចំនួន រេហ៍ពលតិចជាងខ្លួន, កន លែង ប្រើបញ្ញា ដ្បិត យល់ឃើញថា កត្តា ចំនួន ជា កត្តាកំណត់ នៃ វាសនា នៃ សង្គ្រាម។ ចំណែក ព្រះចន្ទរាជា ទ្រង់ វាយយកបាន ខែត្រ ពោធិសាត់ ហើយ តាំង ជាមូលដ្ឋានយោធាចម នៅស្រុក បរិបូណ៌ ព្រោះ ជា តំបន់ សម្បូរ ស្បៀងម្ហូបអាហារ សំរាប់ ចិញ្ចឹមកងទ័ព ដែល ទ្រង់ មាន ផម្នារម្មណ៏ ថា សង្គ្រាម វានឹងមាន រយៈពេលយូរអន្លាយ។ ពីដំបូងទី ព្រះអង្គ ធ្វើសង្គ្រាម ការពារ ទុកឱ្យសត្រូវ លើកទ័ព ដ៏មានចម្ងាយ

42 ល័ព្ធ : គុ. ដែលស្រេចហើយ។
43 អភិ៏ញ្ញាត : ន. ដែលប្រាកដ, ដែលចេះចាំស្ទាត់ប្រាកដ។

# សង្គ្រាម គ្នាឯង

ដំឆ្ងាយ មក វាយ មូលដ្ឋាន របស់ ព្រះអង្គ ដែល អនុញ្ញាត ឱ្យព្រះអង្គ មាន ពេលវេលា រៀបចំ ការវាយប្រហារគោល (attaque ciblée) កងទ័ពសត្រូវ។ ជ័យជំនះ របស់ ព្រះចន្ទរាជា នៅគ្រប់សមរភូមិ សុទ្ធតែ ឈ្នះ ដោយប្រើ កលល្បិចសឹក គឺ ការវាយឆ្មក់ និង បង្អាប់កងទ័ព រង់ចាំវាយ។ បន្ថែមពីលើនេះទៀត ព្រះចន្ទរាជា ប្រើសង្គ្រាម ចិត្តសាស្ត្រ ដូចយ៉ាង តាមឿង សម្លាប់ ខ្លួន ទៅ កេណ្ឌទ័ពបិសាច, នយោបាយ អត់ឱនទោស ដល់ អស់អ្នកចាញ់ និង ឃោសនា ថា ព្រះអង្គ ជា ស្តេច ពេញសិទ្ធិ ព្រោះ ព្រះអង្គ ជា វរវង្ស ក្រុងកម្ពុជាធិបតី។ តែ ព្រះអង្គ ក៏បង្ហាញ វិរសម្បត្តិ ព្រះអង្គ ជា ស្តេច ស្រឡាញ់ សន្តិភាព និង មាន ទសពិធរាជធម៌ ដោយ យក ក្រស័ត្រ ជា សីលធម៌សឹក។

វិសិដ្ឋភាព របស់ ព្រះចន្ទរាជា លើ ស្តេចកន ទាំង ចិត្តសាស្ត្រ និង យុទ្ធសាស្ត្រ ជា កត្តា កំណត់ នៃ ជ័យជំនះ ព្រះចន្ទរាជា លើ ស្តេចកន នោះឯង។ ព្រះអង្គ ធ្វើសង្គ្រាម ដើម្បី ឯកភាពជាតិ ដាច់ខាត, ចំណែក ស្តេចកន ធ្វើសង្គ្រាម ដើម្បី បំបែក ស្រុកខ្មែរ ជា ពីរ តំបន់ រាជ្យ ដែល នាំបង្ហាញ នូវ រូបភាព ជា ស្តេចខ្សោយ នៅចំពោះមុខសត្រូវ និង អាណាប្រជារាស្ត្រផង។ ដូច្នេះ នៅទីណា ដែល មាន ឆន្ទៈ ត្រឹមត្រូវ គឺ បើកផ្លូវ ទៅរក ជ័យជំនះ, ឆន្ទៈ កំណត់ នេះឯង ដែល ព្រះចន្ទរាជា យកមកធ្វើ ជាមធ្យោបាយ សំរាប់ យក ឈ្នះសត្រូវ៕